ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន
MINISTRY OF INFORMATION

# ផែនការយុទ្ធសាស្ត្រ
## អភិវឌ្ឍន៍វិស័យព័ត៌មាននិងសោតទស្សន៍
## ឆ្នាំ២០២៤-២០២៨

បង្កើនប្រសិទ្ធភាពស្ថាប័នទំនាក់ទំនងសាធារណៈរបស់រាជរដ្ឋាភិបាល
ប្រកបដោយ «*បុរេសកម្ម សកម្ម អន្តរសកម្ម ប្រសិទ្ធភាព និងប្រសិទ្ធផល*» ដើម្បី
គ្រប់គ្រងសណ្តាប់ធ្នាប់សារព័ត៌មាន ធានាបានសន្តិសុខព័ត៌មាន និងសុខដុមនីយកម្មសង្គម

**ខែសីហា ឆ្នាំ២០២៤**

# មាតិកា


**បុព្វកថា** ........................................ i

**ខ្លឹមសារសង្ខេប** ........................................ iv

**១. សេចក្តីផ្តើម** ........................................ ១

១.១. សាវតារ ........................................ ១

១.២. អាទិភាពនៃការអភិវឌ្ឍវិស័យព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ........................................ ២

១.៣. បញ្ហាប្រឈម ........................................ ៤

១.៤. គោលការណ៍ជាមូលដ្ឋាន ........................................ ៤

**២. ចក្ខុវិស័យ** ........................................ ៨

**៣. បេសកកម្ម** ........................................ ៨

**៤. គោលដៅ គោលបំណង និងគុណតម្លៃ** ........................................ ៩

**៥. ក្របខណ្ឌយុទ្ធសាស្ត្រ** ........................................ ១០

៥.១. ការវិភាគជាយុទ្ធសាស្ត្រ ........................................ ១០

៥.២. ទិសដៅយុទ្ធសាស្ត្រ ........................................ ១១

៥.៣. យុទ្ធសាស្ត្រ ........................................ ១១

**៦. ផែនការសកម្មភាព** ........................................ ១១

៦.១. ផែនការរយៈពេលខ្លី (ឆ្នាំ២០២៤) ........................................ ១១

ក. ការពង្រឹងសមត្ថភាពនិងប្រសិទ្ធភាពស្ថាប័ន និងគុណភាពការងារ ........................................ ១១

ខ. ការផ្លាស់ប្តូរការផ្សាយទូរទស្សន៍ពីប្រព័ន្ធអាណាឡូកទៅឌីជីថល ........................................ ១២

គ. ការគ្រប់គ្រងសណ្តាប់ធ្នាប់សារព័ត៌មាន ........................................ ១៣

៦.២. ផែនការរយៈពេលវែង (ឆ្នាំ២០២៤-២០២៨) ........................................ ១៤

១. ការធ្វើទំនើបកម្មស្ថាប័ននិងការកសាងរដ្ឋបាលទំនើប ........................................ ១៥

២. ការពង្រឹងបទដ្ឋានបច្ចេកទេសនិងការទទួលខុសត្រូវវិជ្ជាជីវៈ ........................................ ១៨

៣. ការអភិវឌ្ឍធនធានមនុស្សនិងបណ្តុះស្មារតីមនសិការវិជ្ជាជីវៈ ........................................ ២១

៤. ការរៀបចំប្រព័ន្ធនិងយន្តការគ្រប់គ្រងលំហព័ត៌មាន ........................................ ២៣

៥. ការបង្កើនភាពជាដៃគូប្រកបដោយបរិយាប័ន្ននិងស័ក្តិសិទ្ធភាព ........................................ ២៦

**៧. យន្តការដឹកនាំ និងអនុវត្ត** ........................................ ៣១

**៨. ប្រភពថវិកា និងធនធានហិរញ្ញវត្ថុ** ........................................ ៣១

**៩. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** ........................................ ៣២

**១០. សេចក្តីសន្និដ្ឋាន** ........................................ ៣២

**ឧបសម្ព័ន្ធ** ........................................ ៣៤

# **បុព្វកថា**

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** និងបន្តដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅក្នុងរាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧ នៃរដ្ឋសភា, ក្រសួងព័ត៌មាន បានបន្តខិតខំអនុវត្តការងារប្រកបដោយស្មារតីទទួលខុសត្រូវក្នុងកម្រិតវិជ្ជាជីវៈខ្ពស់។ ក្រសួងបានផ្តោតការយកចិត្តទុកដាក់លើការពង្រឹង និងពង្រីកវិសាលភាពនៃការផ្សព្វផ្សាយ ឱ្យបានកាន់តែទូលំទូលាយ តាមរយៈយន្តការប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងប្រព័ន្ធផ្សព្វផ្សាយទំនើប ក្នុងគោលបំណងផ្តល់នូវឱកាស និងលទ្ធភាពពេញលេញជូនដល់ពលរដ្ឋនៅគ្រប់ទិសទី ដើម្បីទទួលបានព័ត៌មានពិតតាមតម្រូវការនិងទាន់ហេតុការណ៍ ក្រោមអភិក្រម «**ប្លែក លឿន ទុកចិត្តបាន ពេលណា ទីណា ក៏ទទួលបាន**»។

ក្រសួងព័ត៌មានបានដើរតួនាទីយ៉ាងសកម្មក្នុងការអនុវត្តនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ដោយបានតម្រង់ទិសការងាររបស់ខ្លួនលើការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យព័ត៌មាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពកិច្ចការព័ត៌មាននិងសោតទស្សន៍ ការផ្សព្វផ្សាយតាមគ្រប់រូបភាព កិច្ចការរដ្ឋបាលទូទៅ និងការផ្តល់សេវាគាំទ្រលើកកម្ពស់វិស័យព័ត៌មានថ្នាក់ក្រោមជាតិ។ ជាមួយទិសដៅនេះ ក្រសួងព័ត៌មានបានកំណត់សូចនាករចំនួន ៥ រួមមាន (១). *ការផ្លាស់ប្តូរប្រព័ន្ធទូរទស្សន៍អាណាឡូកទៅឌីជីថល* (២). *ការអភិវឌ្ឍវិស័យព័ត៌មាន* (៣). *ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈសារព័ត៌មាន* (៤). *ការប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្លែងក្លាយ* និង (៥). *ការកសាងមូលដ្ឋានគតិយុត្តនិងការពង្រឹងការអនុវត្តច្បាប់*។

ការអនុវត្តដើម្បីសម្រេចបាននូវសូចនាករខាងលើ តែងជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ព្រោះថា បច្ចុប្បន្ន ការរីកចម្រើនផ្នែកសេដ្ឋកិច្ច សង្គម និងបច្ចេកវិទ្យាព័ត៌មានវិទ្យា បានជះឥទ្ធិពលខ្លាំងលើលំហព័ត៌មាន និងកិច្ចសហការដើម្បីធានាបាននូវសន្តិសុខព័ត៌មានកម្ពុជា។ ទន្ទឹមនេះដែរ ការវិវត្តនៃបរិយាកាសភូមិសាស្ត្រនយោបាយ ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងវិបត្តិសកល បានជះឥទ្ធិពលជាអវិជ្ជមាន និងរាំងស្ទះដល់ការខិតខំប្រឹងប្រែងនេះ។ កត្តាមួយចំនួនត្រូវបានកំណត់ជាអាទិភាពក្នុងការងារគ្រប់គ្រង រួមមាន *កត្តាធនធានមនុស្សនិងការងារចាត់តាំង* *ការងាររដ្ឋបាល* និង *ការគ្រប់គ្រងអង្គភាពផ្សព្វផ្សាយនិងអ្នកសារព័ត៌មាន*។ ទន្ទឹមនឹងនេះដែរ ការរីកចម្រើនផ្នែកបច្ចេកវិទ្យា ការវិវត្តនៃសង្គម និងភាពសម្បូណ៌បែបនៃប្រព័ន្ធផ្សព្វផ្សាយ នៃយុគបដិវត្តឧស្សាហកម្ម ៤.០ ការសាយភាយព័ត៌មានមិនពិត ក៏បានជះឥទ្ធិពលខ្លាំងមកលើលំហព័ត៌មាន និងសន្តិសុខព័ត៌មានកម្ពុជា ដោយមានការបង្កើតព័ត៌មានមិនត្រឹមត្រូវ ព័ត៌មានក្លែងក្លាយ និងព័ត៌មានបំពុលសង្គម ក្នុងគោលបំណងបង្កវិទ្ធង្សនាញុះញ៉ង់បំផ្លាញ ឬបង្ខូចកិត្តិយសនិងសេចក្តីថ្លៃថ្នូរ និងព័ត៌មានប្រតិកិរិយា ដែលមានបំណងធ្វើវិច្ឆេទកម្មនយោបាយជាដើម។

ទន្ទឹមនេះដែរ ក្រសួងព័ត៌មានដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃ**

**ព្រះរាជាណាចក្រកម្ពុជា** បានធ្វើកំណែទម្រង់ការងារមិនឈប់ឈរ ដើម្បីដាក់ចេញនូវវិធានការឆ្លើយតបដ៏សមស្រប និងទាន់សភាពការណ៍ជាក់ស្តែង រួមជាមួយការអភិវឌ្ឍវិស័យព័ត៌មាន ការកសាងនិងបង្កើនសមត្ថភាពវិជ្ជាជីវៈសារព័ត៌មាន ការប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្លែងក្លាយ ដោយឈរលើមូលដ្ឋានគតិយុត្ត និងពង្រឹងប្រសិទ្ធភាពការអនុវត្តច្បាប់ និងក្រមសីលធម៌វិជ្ជាជីវៈ។ ជាលទ្ធផល ក្រសួងព័ត៌មានបានរួមចំណែកអនុវត្តដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណទាំង ៤ ដំណាក់កាល និងការរួមចំណែកក្នុងការឆ្លើយតបវិបត្តិនយោបាយសកល ការរីករាលដាលនៃជំងឺកូវីដ-១៩ និងការផ្សព្វផ្សាយព័ត៌មានលម្អិតពីកម្ពុជាជូនប្រជាពលរដ្ឋ និងសាធារណជន។

ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា ផ្អែកលើបទពិសោធដឹកនាំប្រទេសជាង ៤០ឆ្នាំ ដែលបាននាំកម្ពុជាឆ្លងកាត់នូវបរិវត្តកម្មជាច្រើន ដោយបានប្រែក្លាយប្រទេសពីការហែកហួរដោយសង្គ្រាមនិងអំពើប្រល័យពូជសាសន៍មិនធ្លាប់មានក្នុងរយៈពេល៥០០ឆ្នាំ ទៅជាប្រទេសដែលពោរពេញដោយសុខសន្តិភាព មានស្ថិរភាពនយោបាយ សន្តិសុខនិងសណ្តាប់ធ្នាប់សង្គម សាមគ្គីភាពផ្ទៃក្នុងជាតិ ការគោរពសិទ្ធិមនុស្ស និងជាប្រទេសមានការអភិវឌ្ឍដ៏ឆាប់រហ័ស នឹងបន្តផ្តោតលើការអភិវឌ្ឍដោយចីរភាពនិងបរិយាប័ន្ន តាមរយៈការគិតគូរលើប្រព័ន្ធសន្តិសុខសង្គម ការការពារបរិស្ថាននិងប្រយុទ្ធប្រឆាំងការប្រែប្រួលអាកាសធាតុ និងការជំរុញកំណើនផ្នែកសេដ្ឋកិច្ចនិងសង្គមឌីជីថល ដោយសម្លឹងឆ្ពោះទៅបង្គោលចរណ៍ «**ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០**»។

ឈរលើមូលដ្ឋាននេះ ក្រសួងព័ត៌មាននឹងបន្តពង្រឹងខ្លួនឱ្យកាន់តែរឹងមាំ ដើម្បីបង្កើននិងពង្រឹងប្រសិទ្ធភាពក្នុងនាមជា*ស្ថាប័នទំនាក់ទំនងសាធារណៈរបស់រាជរដ្ឋាភិបាល ប្រកបដោយបុរេសកម្ម សកម្មអន្តរសកម្ម ប្រសិទ្ធភាព និងប្រសិទ្ធផល* ដើម្បីគ្រប់គ្រងសណ្តាប់ធ្នាប់សារព័ត៌មាន លំហព័ត៌មាន និងធានាបាននូវសន្តិសុខព័ត៌មាន និងសុខដុមនីយកម្មសង្គម។ ក្រសួងព័ត៌មាន នឹងបន្តការលើកកម្ពស់សិទ្ធិទទួលបានព័ត៌មាន ដែលមានបេសកកម្មផ្តោតជាអាទិភាពលើការធ្វើទំនើបកម្មស្ថាប័ននិងការកសាងរដ្ឋបាលទំនើប ការដាក់វិធានការលើកកម្ពស់និងពង្រឹងក្របខណ្ឌច្បាប់និងបទដ្ឋានបច្ចេកទេស ការអភិវឌ្ឍមូលធនមនុស្ស និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ ការរៀបចំប្រព័ន្ធនិងយន្តការគ្រប់គ្រងលំហព័ត៌មាន និងការបង្កើនភាពជាដៃគូប្រកបដោយបរិយាប័ន្ននិងស័ក្តិសិទ្ធភាព ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០២៤-២០២៨ និងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជាឆ្នាំ២០២២-២០៣៥ ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្ត **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** ដើម្បីសម្រេចបាននូវការពង្រឹងនិងកែទម្រង់ស្ថាប័ន ការលើកកម្ពស់និងពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ ការលើកកម្ពស់សមត្ថភាពធនធានមនុស្សនិងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ ការលើកកម្ពស់និងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ក្នុងវិស័យព័ត៌មាន ធានាសិទ្ធិទទួលព័ត៌មាន ការពង្រឹងការគោរពក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មាននិងការពង្រឹងអភិបាលកិច្ចនៃភាពជាដៃគូ ក្នុងគោលដៅធានាឱ្យបាននូវសន្តិសុខព័ត៌មាន ក្រោមអភិក្រម «**ថ្មី ពិត និងទូលំទូលាយ ប្រកប ដោយជំនឿទុកចិត្តនិងវិជ្ជាជីវៈ ដើម្បីផ្សារភ្ជាប់គ្រប់មជ្ឈដ្ឋាន**»។

ក្នុងន័យនេះ ដើម្បីបង្កើនប្រសិទ្ធភាពការងារ ក្នុងបរិបទនៃការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងសង្គម និង ដើម្បីលើកកម្ពស់ប្រសិទ្ធផលស្ថាប័ន ក្រសួងព័ត៌មាន បានកំណត់នូវទិសដៅអាទិភាពជាយុទ្ធសាស្ត្រសម្រាប់ ជំរុញដំណើរការការដ្ឋានកំណែទម្រង់ជំហានបន្ទាប់ (ឆ្នាំ២០២៣-២០២៨) ដោយឈរលើគោលការណ៍ជា មូលដ្ឋានគ្រឹះទាំង៥ នៃ **ភាពជាអ្នកដឹកនាំ ប្រសិទ្ធភាពស្ថាប័ននិងគុណភាពការងារ មូលធនមនុស្ស ពង្រឹងការអនុវត្តច្បាប់** និង **កិច្ចសហប្រតិបត្តិការការទូតព័ត៌មាន** រួមជាមួយនឹងគុណតម្លៃនៃការ ប្រតិបត្តិ ដើម្បីធានានូវស្តង់ដារប្រតិបត្តិប្រកបដោយភាពស្មោះត្រង់ ជឿជាក់ ការផ្តល់នូវតម្លៃនិងសីលធម៌ ក្នុងការងារ (**សុចរិតភាព**) ការប្រើប្រាស់ចំណេះដឹង និងគំនិតច្នៃប្រឌិតឱ្យអស់លទ្ធភាពនៅក្នុងការវិភាគ ការចូលរួម និងការធ្វើសេចក្តីសម្រេចចិត្ត (**ឧត្តមភាព**) ការលើកទឹកចិត្តឱ្យមានការចូលរួមពីគ្រប់អ្នក ពាក់ព័ន្ធដើម្បីធ្វើការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព និងការចែករំលែកបទពិសោធ និងចំណេះដឹង (**ការចូលរួម**) ការលើកកម្ពស់ការទទួលខុសត្រូវចំពោះសកម្មភាពនិងការសម្រេចចិត្ត (**គណនេយ្យភាព**) និងការបើកចំហរព័ត៌មានជាសាធារណៈ (**តម្លាភាព**)។

ឈរលើមូលដ្ឋាននៃការបន្តកំណែទម្រង់ ក្រោមការដឹកនាំដ៏ត្រឹមត្រូវនិងឈ្លាសវៃប្រកបដោយភាព ប្រាកដនិយម និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងព័ត៌មានជឿជាក់យ៉ាងមុតមាំថានឹងអាចឈានឆ្ពោះទៅសម្រេចបាន នូវការដ្ឋានកំណែទម្រង់ដើម្បីប្រសិទ្ធភាព និងប្រសិទ្ធផលការងារ តាមរយៈការធ្វើទំនើបកម្មស្ថាប័ននិងការ កសាងនូវរដ្ឋបាលទំនើប ការចាត់វិធានការពង្រឹងបទដ្ឋានបច្ចេកទេសនិងការទទួលខុសត្រូវវិជ្ជាជីវៈ ការផ្តោត លើការអភិវឌ្ឍធនធានមនុស្ស និងបណ្តុះស្មារតីមនសិការវិជ្ជាជីវៈ ការជំរុញរៀបចំប្រព័ន្ធនិងយន្តការ គ្រប់គ្រងលំហព័ត៌មាន ដើម្បីធានាបាននូវសន្តិសុខព័ត៌មាន និងការបង្កើនភាពជាដៃគូប្រកបដោយបរិយាប័ន្ន និងស័ក្តិសិទ្ធភាពដើម្បីការពារកេរ្តិ៍ឈ្មោះនិងកិត្យានុភាពជាតិ៕

ថ្ងៃពុធ ២រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**នេត្រ ភក្ត្រា**

# ខ្លឹមសារសង្ខេប

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យព័ត៌មាន និងសោតទស្សន៍ ឆ្នាំ២០២៤-២០២៨** របស់ក្រសួងព័ត៌មាន គឺជាផែនការអាណត្តិកាលសម្រាប់រយៈពេល៥ឆ្នាំ ដែលត្រូវបានរៀបចំដើម្បីចូលរួមលើកកម្ពស់ការដ្ឋានកំណែទម្រង់របស់រាជរដ្ឋាភិបាល លើវិស័យព័ត៌មាន និងសោតទស្សន៍។ ក្នុងគោលបំណងជំរុញការកសាងនិងអភិវឌ្ឍធនធានមនុស្ស រក្សានូវសណ្តាប់ធ្នាប់សារព័ត៌មាន បង្កើនគុណភាពមាតិកា ខ្លឹមសារនិងការផលិត គណៈកម្មាធិការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យព័ត៌មាន និងសោតទស្សន៍ របស់ក្រសួងព័ត៌មាន ត្រូវបានបង្កើតដើម្បីដឹកនាំ និងតម្រង់ទិសការសិក្សា ស្រាវជ្រាវ និងរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រ ព្រមទាំងវិភាគ ផ្តល់យោបល់ និងផ្តល់ទស្សនាទានលើបញ្ហាប្រឈម និងឱកាស ផ្អែកលើមូលដ្ឋានសេដ្ឋកិច្ច សង្គមនិងនយោបាយ ដើម្បីពង្រីកសក្តានុភាព តាមរយៈការរៀបចំកម្មវិធី/សកម្មភាពឆ្លើយតបនឹងតម្រូវការក្នុងវិស័យព័ត៌មាន និងសោតទស្សន៍។

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យព័ត៌មាន និងសោតទស្សន៍ ឆ្នាំ២០២៤-២០២៨** ត្រូវបានរៀបចំឡើង ដើម្បីកំណត់ពីការរួមចំណែកគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ឆ្នាំ២០២២-២០៣៥ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០២៤-២០២៨។ ក្នុងន័យនេះ ក្រសួងព័ត៌មានបានកំណត់នូវទិសដៅយុទ្ធសាស្ត្រចំនួន ៥ គឺ ទី(១). ***ការធ្វើទំនើបកម្មស្ថាប័ននិងការកសាងរដ្ឋបាលទំនើប*** ទី(២). ***ការពង្រឹងបទដ្ឋានបច្ចេកទេសនិងការទទួលខុសត្រូវវិជ្ជាជីវៈ*** ទី(៣). ***ការអភិវឌ្ឍធនធានមនុស្សនិងបណ្តុះស្មារតីមនសិការវិជ្ជាជីវៈ*** ទី(៤). ***ការរៀបចំប្រព័ន្ធនិងយន្តការគ្រប់គ្រងលំហាព័ត៌មាន*** និងទី(៥). ***ការបង្កើនភាពជាដៃគូប្រកបដោយបរិយាប័ន្ន និងស័ក្តិសិទ្ធភាព***។ ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំដោយបានបន្ស៊ីគ្នាជាមួយផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងព័ត៌មាន និងជាមូលដ្ឋានសម្រាប់គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្នុងការរៀបចំផែនការសកម្មភាពនិងសំណើរថវិកាប្រចាំឆ្នាំផងដែរ។

ការអនុវត្តផែនការនេះត្រូវពឹងផ្អែកលើប្រភពថវិការបស់រាជរដ្ឋាភិបាល ឬថវិកាកម្មវិធី និងត្រូវស្វែងរកហិរញ្ញប្បទានគាំទ្របន្ថែមពីដៃគូអភិវឌ្ឍន៍នានា។ តាមរយៈផែនការយុទ្ធសាស្ត្រនេះ ក្រសួងព័ត៌មានរំពឹងថានឹងសម្រេចបាននូវទិសដៅជាយុទ្ធសាស្ត្រចំនួន ៥ គឺ ***ទី១.*** កំណែទម្រង់ការគ្រប់គ្រង និងដំណើរការការងាររដ្ឋបាលដើម្បីធានានូវប្រសិទ្ធភាពនិងគុណភាពការងារ ***ទី២.*** ការកំណត់បទដ្ឋានច្បាប់/ គតិយុត្ត និងបទដ្ឋានបច្ចេកទេស ព្រមទាំងប្រព័ន្ធវាយតម្លៃការងារ ***ទី៣.*** ការកសាង និងអភិវឌ្ឍសមត្ថភាពជំនាញគ្រប់គ្រងដឹកនាំ និងជំនាញបច្ចេកទេស ***ទី៤.*** ការគ្រប់គ្រងលំហាព័ត៌មានប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពដោយផ្អែកលើមូលដ្ឋាននៃការផ្តល់ព័ត៌មានទូលំទូលាយ និងទាន់សភាពការណ៍ប្រកបដោយគុណភាពនិងសុវត្ថិភាព និង ***ទី៥.*** ការលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូ ក្នុងក្របខណ្ឌទ្វេភាគីនិងពហុភាគីដើម្បីផលប្រយោជន៍រួម។ ទន្ទឹមនេះ គណៈកម្មាធិការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍

វិស័យព័ត៌មាន និងសោតទស្សន៍ របស់ក្រសួងព័ត៌មានដឹកនាំការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ដោយមានលេខាធិការដ្ឋាននៃគណៈកម្មាធិការនេះ ជាជំនួយការ។

ដើម្បីជំរុញប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ក្រុមការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ និងគោលនយោបាយរបស់ក្រសួងព័ត៌មាន ត្រូវបានបង្កើតដើម្បីជំរុញការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពការងារក្រសួង ផ្អែកលើអភិក្រម «*ពង្រឹងនិងការរៀបចំផ្ទះរបស់ខ្លួនឱ្យរៀបរយ*» ដោយត្រូវសម្របសម្រួលរួម និងណែនាំដល់អង្គភាពចំណុះក្រសួងលើកិច្ចការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ និងគោលនយោបាយនានា របស់ក្រសួងព័ត៌មាន និងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើសកម្មភាពនៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨ ក្នុងក្របខ័ណ្ឌក្រសួងព័ត៌មាន។ ក្រសួងព័ត៌មានត្រូវរៀបចំសូចនាករសមិទ្ធកម្មគន្លឹះ សម្រាប់ការតាមដាន និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។

សន្និបាតបូកសរុបសមិទ្ធផលប្រចាំឆ្នាំការងារព័ត៌មាន និងសោតទស្សន៍ និងលើកទិសដៅការងារបន្ត គឺជាយន្តការពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាពរបស់អគ្គនាយកដ្ឋាន និងអង្គភាពជំនាញចំណុះឱ្យក្រសួង ដើម្បីឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យព័ត៌មាន និងសោតទស្សន៍ឆ្នាំ ២០២៤-២០២៨៕

# ក្របខណ្ឌយុទ្ធសាស្ត្រ
# អភិវឌ្ឍន៍វិស័យព័ត៌មាន និងសោតទស្សន៍ ឆ្នាំ២០២៤-២០២៨

*បង្កើនប្រសិទ្ធភាពស្ថាប័នទំនាក់ទំនងសាធារណៈរបស់រាជរដ្ឋាភិបាល*
*ប្រកបដោយ «បុរេសកម្ម សកម្ម អន្តរសកម្ម ប្រសិទ្ធភាព និងប្រសិទ្ធផល»*




បង្កើនប្រសិទ្ធភាពនៃយន្តការផ្សព្វផ្សាយស្តីពីឯករាជ្យភាព អធិបតេយ្យភាពនិងបូរណភាពទឹកដីពេញលេញ សុខសន្តិភាព សុវត្ថិភាពនិងសណ្តាប់ធ្នាប់សង្គម ការអភិវឌ្ឍរីកចម្រើននិងមូលដ្ឋានសេដ្ឋកិច្ចរឹងមាំ រួមជាមួយការគោរពលទ្ធិប្រជាធិបតេយ្យ គោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូរ និងកិច្ចសហប្រតិបត្តិការរឹងមាំ ក្នុងនិម្មាបនកម្ម និងរចនាសម្ព័ន្ធសណ្តាប់ធ្នាប់អន្តរជាតិ ដើម្បីឆ្ពោះទៅសម្រេចបាន

**"ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០"**

# ផែនការយុទ្ធសាស្ត្រ
# អភិវឌ្ឍន៍វិស័យព័ត៌មាន និងសោតទស្សន៍
# ឆ្នាំ២០២៤-២០២៨

## ១. សេចក្តីផ្តើម

### ១.១. សាវតារ

វិស័យព័ត៌មាន បានចូលរួមចំណែកដ៏សំខាន់ក្នុងទិសដៅកសាងឱ្យបាននូវអភិបាលកិច្ចល្អ ដោយប្រើប្រាស់គ្រប់មធ្យោបាយផ្តល់ព័ត៌មាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈ ប្រកបដោយតម្លាភាព គណនេយ្យភាព និងភាពស័ក្តិសិទ្ធិ ក្នុងគោលបំណងចូលរួមបេសកកម្មដ៏ឧត្តុង្គឧត្តមក្នុងកិច្ចថែរក្សានិងការពារសមិទ្ធផលដ៏ធំធេងរបស់ជាតិកម្ពុជា ការពារសន្តិភាព ស្ថិរភាព សុវត្ថិភាពនិងសណ្តាប់ធ្នាប់សង្គម និងការអភិវឌ្ឍប្រទេស។ ការគ្រប់គ្រងលំហព័ត៌មាន និងសន្តិសុខព័ត៌មាន មានភាពប្រទាក់ក្រឡា និងជានិច្ចកាលទទួលនូវឥទ្ធិពលពីការជ្រៀតជ្រែករបស់ប្រព័ន្ធផ្សព្វផ្សាយបរទេស ដែលក្នុងករណីមួយចំនួន ជាការប៉ុនប៉ងប្រែក្លាយសភាពការណ៍កម្ពុជា តាមរយៈព័ត៌មានក្លែងក្លាយ មិនមានប្រភពច្បាស់លាស់ ឬជាព័ត៌មានញុះញង់បំភ្លៃការពិត។

ក្នុងគោលបំណងរួមចំណែកការពារសន្តិភាព ស្ថេរភាព និងសន្តិសុខ រួមជាមួយការលើកស្ទួយសិទ្ធិសេរីភាពខាងសារព័ត៌មាន សេរីភាពក្នុងការបញ្ចេញមតិ និងការបើកទូលំទូលាយក្នុងការផ្តល់ព័ត៌មានទូទាំងកម្ពុជា ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីរបបសារព័ត៌មាន និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រសួងព័ត៌មានបានរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៨-២០២៣ ដោយបានដាក់ចេញនូវគោលដៅចំពោះមុខលើការធ្វើសមាហរណកម្មប្រព័ន្ធផ្សព្វផ្សាយឌីជីថលក្នុងតំបន់ និងសកល (ការផ្លាស់ប្តូរប្រព័ន្ធទូរទស្សន៍ពីអាណាឡូកទៅឌីជីថល) ការអភិវឌ្ឍវិស័យព័ត៌មាន ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈសារព័ត៌មាន ការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយនិងរក្សាសន្តិសុខព័ត៌មាន និងការកសាងមូលដ្ឋានគតិយុត្តនិងការពង្រឹងការអនុវត្តច្បាប់ ។

ទន្ទឹមនេះ ក្នុងគោលដៅកសាងស្ថាប័នព័ត៌មានឱ្យមានគុណភាព ប្រសិទ្ធភាព សេចក្តីថ្លៃថ្នូរ និងទទួលបានការគាំទ្រនិងទំនុកចិត្ត ក្រសួងព័ត៌មានបានខិតខំបន្តការអភិវឌ្ឍន៍វិស័យព័ត៌មានដោយផ្តោតលើការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធផ្សព្វផ្សាយព័ត៌មានគ្រប់ប្រភេទ និងការពង្រីកវិសាលភាពនៃការផ្សាយឱ្យកាន់តែទូលំទូលាយនិងគ្របដណ្តប់ទូទាំងប្រទេស តំបន់ និងសកល សម្រាប់ជាមធ្យោបាយក្នុងការបញ្ជ្រាបព័ត៌មានស្តីពីកម្ពុជា និងសមិទ្ធផលនៃការអភិវឌ្ឍប្រទេស។ ស្របគ្នានេះដែរ ការយកចិត្តទុកដាក់លើការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសារព័ត៌មានក៏ត្រូវបានពង្រឹងដើម្បីលើកកម្ពស់គុណភាពព័ត៌មាន និងជំរុញសមាហរណកម្មចំណេះដឹង និងសមត្ថភាពក្នុងបរិការណ៍ នៃការវិវត្តផ្នែកបច្ចេកវិទ្យាប្រព័ន្ធផ្សព្វផ្សាយទំនើប ដែលជាការប្រកួតប្រជែងទីផ្សារឧស្សាហកម្មប្រព័ន្ធផ្សព្វផ្សាយនាពេលបច្ចុប្បន្ន។

ការរីកចម្រើន និងវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថល ក្នុងយុគសម័យបដិវត្តឧស្សាហកម្ម ៤.០ បានជះឥទ្ធិពលខ្លាំងក្លាចំពោះការអភិវឌ្ឍសេដ្ឋកិច្ច និងវិស័យសារព័ត៌មានដោយបានបង្កើតនូវកាលានុវត្តភាពនៃការចាប់យកនូវវិធីសាស្ត្រនៃបច្ចេកវិទ្យាថ្មីៗ ទំនើបទាន់សម័យនិងប្រកបដោយសក្តានុពល ក្នុងការពង្រីកវិសាលភាពនៃប្រព័ន្ធផ្សព្វផ្សាយឱ្យបានលឿនទាន់សភាពការណ៍។ ប៉ុន្តែ ទន្ទឹមនឹងនេះ ការរីកចម្រើនផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យាដែលហួសពីសមត្ថភាពនៃការគ្រប់គ្រង ក៏ជាឱកាសដែលត្រូវបានប្រើប្រាស់ក្នុងន័យប្រឆាំងនឹងរាជរដ្ឋាភិបាល តាមរយៈការបង្កើតព័ត៌មានក្លែងក្លាយ ដើម្បីញុះញង់បង្កឱ្យកើតមានចលាចល អំពើហិង្សា ការរើសអើងពូជសាសន៍ ការបំបែកបំបាក់សាមគ្គីភាពជាតិ និងការអុជអាលបង្កជាជម្លោះជាមួយបរទេសជាដើម។ ជាការឆ្លើយតប ក្រសួងព័ត៌មានបានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធជាតិនិងអន្តរជាតិ និងដៃគូផ្សេងៗ ក្នុងការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់រាល់ព័ត៌មានមិនពិតនិងព័ត៌មានក្លែងក្លាយ ដែលមានប្រភពពីប្រព័ន្ធផ្សព្វផ្សាយគ្រប់ទម្រង់ បង្កឡើងដោយក្រុមអគតិ និងជនឱកាសនិយម ដែលមានគំនិតចង់ផ្តួលរំលំរាជរដ្ឋាភិបាលកម្ពុជាស្របច្បាប់។

សមិទ្ធផលដែលក្រសួងព័ត៌មានទទួលបានកន្លងមក គឺជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងទាំងក្នុងកម្រិតនយោបាយ និងបច្ចេកទេស និងជាពិសេស គឺមូលដ្ឋានគតិយុត្តនិងការពង្រឹងការអនុវត្តច្បាប់ ដែលគិតត្រឹមនីតិកាលទី៦ នៃរដ្ឋសភា ក្រសួងព័ត៌មានបានរៀបចំមូលដ្ឋានគ្រឹះសម្រាប់គាំទ្រប្រតិបត្តិការក្នុងវិស័យព័ត៌មាន ដូចជាសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន និងការសិក្សាលើវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ១៩៩៥ ដើម្បីឆ្លើយតបតាមតម្រូវការនិងស្ថានភាពជាក់ស្តែងនៃការវិវត្តក្នុងវិស័យព័ត៌មាន ក៏ដូចជាសង្គតភាពជាមួយនឹងបទប្បញ្ញត្តិដែលមានជាធរមាន។ ជាមួយនេះដែរ ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពព័ត៌មាន ក្រសួងព័ត៌មានក៏បានជំរុញ និងលើកទឹកចិត្តក្នុងការរៀបចំនិងអនុវត្តក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មាន។

## ១.២. អាទិភាពនៃការអភិវឌ្ឍវិស័យព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ

វិស័យព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាមានការវិវត្តគួរឱ្យកត់សម្គាល់នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ជាពិសេសក្នុងដំណាក់កាលនៃការរីកចម្រើនផ្នែកបច្ចេកវិទ្យា ដែលបាននាំមកនូវប្រព័ន្ធផ្សព្វផ្សាយជំនាន់ថ្មី ដូចជាបញ្ញាសិប្បនិមិត្ត និងការចាប់ផ្តើមនៃប្រព័ន្ធផ្សព្វផ្សាយជំនាន់ទី៥ ជាដើម។ ក្នុងដំណាក់កាលនៃបដិវត្តឧស្សាហកម្ម ៤.០ ដើម្បីជំរុញសមាហរណកម្មប្រព័ន្ធផ្សព្វផ្សាយ អាទិភាពការងារដែលកម្ពុជាត្រូវបន្តគឺ៖

***ការផ្លាស់ប្តូរប្រព័ន្ធផ្សាយពីអាណាឡូកទៅឌីជីថល៖*** ស្របតាមការប្តេជ្ញាចិត្តរួមរបស់អាស៊ាន ប្រទេសកម្ពុជាត្រូវផ្លាស់ប្តូរប្រព័ន្ធផ្សាយពីអាណាឡូកទៅឌីជីថលឱ្យបានត្រឹមចុងឆ្នាំ២០២៥។ ការផ្សាយតាមឌីជីថលផ្តល់នូវគុណភាពផ្សាយទាំងរូបភាព និងសំឡេង ហើយអ្នកទស្សនិកជនអាចទស្សនាមាតិកាដែលមានគុណភាពកម្រិតខ្ពស់។ ការផ្សាយតាមប្រព័ន្ធឌីជីថលអនុញ្ញាតឱ្យមានការបញ្ជូនប៉ុស្តិ៍បានច្រើននៅលើប្រេកង់ស៍ដូចគ្នា ដែលខុសពីប្រព័ន្ធផ្សាយអាណាឡូកដែលប្រេកង់ស៍មួយផ្ទុកការផ្សាយបានមួយប៉ុស្តិ៍ប៉ុណ្ណោះ។ ជាមួយតម្លៃកាន់តែទាប ប្រព័ន្ធផ្សាយឌីជីថលដែលធ្វើឱ្យមាតិកានៃការផ្សាយមានភាពសម្បូរបែប និងការផ្សព្វផ្សាយនូវកម្មវិធីចម្រុះកាន់តែច្រើនដើម្បីបំពេញតម្រូវការ។ ការជំរុញប្រព័ន្ធផ្សាយតាមឌីជីថល នឹងលើកកម្ពស់នូវសិទ្ធិទទួលព័ត៌មានរបស់ប្រជាពលរដ្ឋផងដែរ។

***ការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយ៖*** បច្ចេកវិទ្យាក្នុងប្រព័ន្ធផ្សព្វផ្សាយមានការរីកចម្រើនឥតឈប់ឈរ និងប្រែប្រួលទៅតាមការវិវត្តនៃសេដ្ឋកិច្ច។ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការផ្សព្វផ្សាយ និងពង្រីកវិសាលភាពនៃប្រព័ន្ធផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងលឿនទាន់សភាពការណ៍ ប្រព័ន្ធបច្ចេកវិទ្យារួមទាំងប្រព័ន្ធភាពទន់ពាក់ព័ន្ធវិស័យព័ត៌មានត្រូវមានការធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍជាប្រចាំ ដើម្បីបង្កើនគុណភាពនៃសេវាកម្មទូរទស្សន៍ និងវិទ្យុ និងការប្រើប្រាស់ទូទាំងប្រទេស។ ការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយមានទំនាក់ទំនងយ៉ាងសកម្មទៅនឹងកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់ឧស្សាហកម្ម ៤.០ ដើម្បីធ្វើឱ្យប្រទេសកម្ពុជាក្លាយជាសេដ្ឋកិច្ចឌីជីថលពេញលេញ។

***ការលើកទឹកចិត្តដល់ប្រព័ន្ធផ្សព្វផ្សាយ៖*** ប្រព័ន្ធផ្សព្វផ្សាយទាំងរដ្ឋនិងឯកជន ត្រូវបានទទួលការលើកទឹកចិត្តពីរាជរដ្ឋាភិបាល ក្រសួងសាមី និងក្រសួងស្ថាប័នពាក់ព័ន្ធទាំងការលើកទឹកចិត្តហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុដើម្បីបង្កើនប្រសិទ្ធភាព និងគុណភាពនៃការផ្សព្វផ្សាយ។ ជារួម កន្លងមករាជរដ្ឋាភិបាល និងក្រសួងព័ត៌មាន បានអនុវត្តកម្មវិធីជាច្រើនដើម្បីលើកកម្ពស់ និងគាំពារអ្នកសារព័ត៌មាន អង្គភាពសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ដូចជាការផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់និងមេធាវីការពារក្តីនៅតុលាការ ការបញ្ចុះតម្លៃសេវាសាធារណៈ និងការលើកលែងពន្ធប៉ាតង់ និងការលើកលែងតម្លៃសេវាចុះបញ្ជិការសម្រាប់ប្រព័ន្ធផ្សព្វផ្សាយអនឡាញតូចតាចនៅក្រសួងពាណិជ្ជកម្ម ការបញ្ចុះតម្លៃលើសេវាពិនិត្យសុខភាព ការធ្វើប្រតិភូកម្មមុខងារទៅថ្នាក់ក្រោមជាតិ។ល។ ការលើកទឹកចិត្តដល់ប្រព័ន្ធផ្សព្វផ្សាយជាប្រតិបត្តិការដ៏សំខាន់មួយ ដែលត្រូវផ្តោតលើការគាំទ្រផ្នែកច្បាប់ ការកសាងនិងអភិវឌ្ឍសមត្ថភាព និងការលើកទឹកចិត្តឱ្យប្រព័ន្ធផ្សព្វផ្សាយចូលរួមយ៉ាងសកម្មក្នុងការផ្តល់ព័ត៌មានដែលទាក់ទងបញ្ហាសង្គម។

***ការរៀបចំបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសសម្រាប់លើកកម្ពស់ការផ្សព្វផ្សាយ៖*** ដើម្បីលើកកម្ពស់ការផ្សព្វផ្សាយឱ្យមានប្រសិទ្ធភាព និងសមិទ្ធផល ទាមទារជាចាំបាច់ឯកសារលិខិតបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសសម្រាប់រក្សាសណ្តាប់ធ្នាប់និងពង្រឹងសន្តិសុខព័ត៌មាន។ ច្បាប់ស្តីពីរបបសារព័ត៌មានដែលត្រូវបានអនុម័តនៅឆ្នាំ១៩៩៥ ជាច្បាប់តែមួយគត់សម្រាប់គ្រប់គ្រងលើវិស័យព័ត៌មាននិងសោតទស្សន៍។ ដោយសារការវិវត្តន៍នៃសង្គម និងការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ច្បាប់ និងឯកសារបទដ្ឋានគតិយុត្តជាច្រើនព្រមទាំងបទដ្ឋានបច្ចេកទេស ត្រូវការបង្កើតឡើងជាចាំបាច់ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការដឹកនាំ និងគ្រប់គ្រងលើវិស័យព័ត៌មាន និងសោតទស្សន៍។

***ការកសាង និងអភិវឌ្ឍធនធានមនុស្ស៖*** ស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និង ផែនការអភិវឌ្ឍន៍ជាតិ (២០២៤-២០២៨) ការកសាង និងអភិវឌ្ឍធនធានមនុស្សគឺជាអទិភាពនៃក្រសួងព័ត៌មានដើម្បីពង្រឹងសមត្ថភាពវិជ្ជាជីវៈរបស់មន្ត្រី និងអ្នកប្រកបអាជីពក្នុងវិស័យព័ត៌មាន និងសោទស្សន៍។ ការកសាង និងអភិវឌ្ឍធនធានមនុស្សតាមរយៈការធ្វើទំនើបកម្មមណ្ឌលបណ្តុះបណ្តាល និងវិក្រិត្តការសារព័ត៌មាន សិក្ខាកាមជាមន្ត្រីនិងអ្នកសារព័ត៌មាននឹងមានសមត្ថភាពក្នុងការបំពេញការងារបានល្អ គោរពតាមក្រមសីលធម៌វិជ្ជាជីវៈ និងអាចចេះប្រើប្រាស់ឧបករណ៍ឆ្លាត និងទំនើប។

***ការផលិតមាតិកា និងខ្លឹមសារ៖*** ការលើកកម្ពស់គុណភាពព័ត៌មាន គឺអាស្រ័យលើការលើកកម្ពស់គុណភាពនៃមាតិកា និងខ្លឹមសារ។ គុណភាពមាតិកា និងខ្លឹមសារ មានសារៈសំខាន់សម្រាប់

ការកសាងទំនុកចិត្ត និងទាក់ទាញការគាំទ្រពីសាធារណជន។ ដោយផ្តោតលើគុណភាព ប្រព័ន្ធផ្សព្វផ្សាយអាចបម្រើទស្សនិកជនរបស់ខ្លួនបានប្រសើរជាងមុន រួមចំណែកជាវិជ្ជមានដល់សង្គម និងនៅតែជាសសរស្តម្ភដ៏សំខាន់នៃលទ្ធិប្រជាធិបតេយ្យ។

## ១.៣. បញ្ហាប្រឈម

ការប្រែប្រួលរចនាសម្ព័ន្ធនិងនិម្មាបនកម្មសេដ្ឋកិច្ច សង្គម និងនយោបាយសកល ជាពិសេស និន្នាការបច្ចេកវិទ្យា និងឌីជីថល (បរិវត្តកម្មឌីជីថល) បានជះឥទ្ធិពលគួរកត់សម្គាល់ដល់វិស័យព័ត៌មាន និងសោតទស្សន៍។ ជាមួយកម្មវិបាកនៃនិន្នាការទាំងនេះ បញ្ហាប្រឈមមួយចំនួនចាំបាច់ត្រូវមានវិធានការដោះស្រាយជាដំណាក់កាល។

ជារួម បញ្ហាប្រឈមដែលជះឥទ្ធិពលដល់វិស័យព័ត៌មាន និងសោតទស្សន៍រួមមានៈ

- តម្រូវការច្បាប់ និងបទដ្ឋានគតិយុត្តសម្រាប់ពង្រឹងវិស័យព័ត៌មាននិងសោតទស្សន៍ស្របតាមការវិវត្តនៃសង្គមនិងបច្ចេកវិទ្យា
- ឥទ្ធិពលនៃបញ្ញាសិប្បនិមិត្ត ដែលនឹងជ្រៀតចូលក្នុងវិស័យសារព័ត៌មាន
- ឥទ្ធិពលលើប្រព័ន្ធផ្សព្វផ្សាយបែបបុរាណ ពីការរីកចម្រើនផ្នែកបច្ចេកវិទ្យាឌីជីថល
- ការរីកចម្រើននៃបច្ចេកវិទ្យាផ្នែកបណ្តាញសង្គម បង្កលក្ខណៈដល់ការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ (បំភ្លៃការពិត មានចរិតបំពុលសង្គម ជេរប្រមាថ និងញុះញង់ បង្កឱ្យកើតមានអវិភាព ការបែកបាក់សាមគ្គីភាពជាតិ)
- ការអភិវឌ្ឍចំណេះដឹងសម្របតាមការរីកចម្រើនផ្នែកបច្ចេកវិទ្យា
- ការបំពានក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មាន
- ការបិទដំណើរការរបស់អង្គភាពសារព័ត៌មានទាំងបែបប្រពៃណី និងបែបទំនើបដោយសារវិបត្តិហិរញ្ញវត្ថុ ដែលបណ្តាលមកពីការធ្លាក់ចុះនៃតម្រូវការ ផលប៉ះពាល់នៃសេដ្ឋកិច្ចសកល ភាពរីកចម្រើននៃបច្ចេកវិទ្យា និងកង្វះភាពជាសហគ្រិន
- ចំណេះដឹងមូលដ្ឋាន និងបទពិសោធការងារអន្តរជាតិរបស់អ្នកសារព័ត៌មានឯកជនមួយចំនួន នៅមានកម្រិត។

## ១.៤. គោលការណ៍ជាមូលដ្ឋាន

### *យុទ្ធសាស្ត្របញ្ចកោណ -ដំណាក់កាលទី១*

យុទ្ធសាស្ត្របញ្ចកោណ -ដំណាក់កាលទី១ បានកំណត់ពីមូលដ្ឋាននៃការបន្តធ្វើកំណែទម្រង់រដ្ឋឱ្យកាន់តែស៊ីជម្រៅ ទូលំទូលាយ មានភាពស៊ីសង្វាក់ប្រទាក់ក្រឡាគ្នា និងគាំទ្រគ្នាលើការដ្ឋានកំណែទម្រង់ស្នូលផ្នែកអភិបាលកិច្ច ទន្ទឹមនឹងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ព្រមទាំងការពង្រឹងអភិបាលកិច្ចវិស័យឯកជននិងធុរកិច្ច សំដៅធានាដល់ការលើកកម្ពស់អភិបាលកិច្ចនៃគ្រប់ក្រសួង ស្ថាប័នគ្រប់ថ្នាក់ ការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាពនិងជំនឿទុកចិត្ត ដោយនឹងត្រូវអនុវត្តឱ្យបានយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍នៃការពង្រឹងនិងកែទម្រង់ស្ថាប័ន ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និងការពង្រឹងប្រសិទ្ធភាព នៃការអនុវត្តការងារ ការលើកកម្ពស់និងពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាល

សាធារណៈ ការលើកកម្ពស់និងការពង្រឹងប្រសិទ្ធភាពនៃច្បាប់និងប្រព័ន្ធយុត្តធម៌ និងការពង្រឹងអភិបាលកិច្ចវិស័យឯកជននិងធុរកិច្ច។

ក្នុងដំណាក់កាល នៃការធ្វើកំណែទម្រង់បន្តរបស់រាជរដ្ឋាភិបាលកម្ពុជា នៅនីតិកាលទី៧ នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២៣-២០២៨ ក្រសួងព័ត៌មានបានធ្វើការសិក្សា និងបានកំណត់ដាក់ចេញនូវទិសដៅអាទិភាពចំនួន៥ នៃក្របខណ្ឌអាទិភាពការងារជាមូលដ្ឋានសម្រាប់ដំណើរការការដ្ឋានកំណែទម្រង់៖ ទី១. ការធ្វើទំនើបកម្មស្ថាប័ននិងការកសាងរដ្ឋបាលទំនើប ទី២. វិធានការលើកកម្ពស់និងពង្រឹងក្របខណ្ឌច្បាប់និងបទដ្ឋានបច្ចេកទេស ទី៣. ការអភិវឌ្ឍធនធានមនុស្សនិងការពង្រឹងប្រសិទ្ធភាពការងារ ទី៤. ការរៀបចំប្រព័ន្ធនិងយន្តការគ្រប់គ្រងលំហព័ត៌មានដើម្បីធានាបាននូវសន្តិសុខព័ត៌មាន និងទី៥. ការបង្កើនភាពជាដៃគូប្រកបដោយបរិយាប័ន្ននិងស័ក្តិសិទ្ធភាព ដើម្បីការពារកេរ្តិ៍ឈ្មោះ និងកិត្យានុភាពជាតិ។

ជាមួយនិន្នាការសកលធំៗ ដែលមានឥទ្ធិពលមកលើកម្ពុជា និងការសម្លឹងទៅមុខ ២៥ឆ្នាំជាបន្តទៀត រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញនូវ ***យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១*** ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដែលនឹងកសាងនូវមូលដ្ឋានរឹងមាំ ដើម្បីឆ្ពោះទៅសម្រេច ***ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០***។ ក្នុងន័យនេះ ក្រសួងព័ត៌មាន នឹងបន្តជំរុញនិងលើកកម្ពស់ការធ្វើកំណែទម្រង់ការងារនិងស្ថាប័ន ដើម្បីសម្របតាមបរិបទនៃការវិវត្តជាសកល តាមរយៈការរៀបចំបន្តនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០២៤-២០២៨។ ជាមួយគ្នានេះដែរ កំណែទម្រង់វិស័យព័ត៌មាននឹងឈរលើមូលដ្ឋាននៃការដោះស្រាយបញ្ហាពាក់ព័ន្ធផ្សេងៗ ដើម្បីលើកកម្ពស់តម្លាភាព ប្រសិទ្ធភាព គណនេយ្យភាព និងសមធម៌ ក្នុងដំណើការប្រតិបត្តិការងារ និងការការពារផលប្រយោជន៍របស់មន្ត្រីរាជការ។ ផ្តើមចេញពីប្រសិទ្ធភាពក្នុងការគ្រប់គ្រងប្រព័ន្ធការងារ បញ្ហាមួយចំនួនត្រូវបានកំណត់ និងចាំបាច់ត្រូវមានវិធានការដោះស្រាយតាមដំណាក់កាល។

## គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥

ក្នុងគោលដៅកសាងរដ្ឋាភិបាលឌីជីថល ដើម្បីលើកកម្ពស់គុណភាពជីវិតនិងទំនុកចិត្តប្រជាពលរដ្ឋតាមរយៈការបម្រើសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ឆ្នាំ២០២២-២០៣៥ សម្រាប់ការអនុវត្តខណៈដែលចរន្តនៃបដិវត្តឧស្សាហកម្មជំនាន់ទី៤ កំពុងតែជះឥទ្ធិពលខ្លាំងលើសេដ្ឋកិច្ច និងសង្គម ទាមរយៈការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត្ត ការវិភាគទិន្នន័យ និងអ៊ីនធឺណែតនៃវត្ថុ។ល។ បច្ចេកវិទ្យាឌីជីថលបានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងលឿនដែលមិនធ្លាប់មានពីមុនក្នុងវិស័យសំខាន់ៗ ជាពិសេសវិស័យព័ត៌មាន និងសោតទស្សន៍ ដែលចាំបាច់ត្រូវរៀបចំការធ្វើបរិវត្តកម្មឌីជីថលទៅក្នុងវិស័យនេះ។

យ៉ាងណាក៏ដោយ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅជួបបញ្ហា ដោយសារការតភ្ជាប់ឌីជីថលនៅមិនទាន់គ្របដណ្តប់ពេញផ្ទៃប្រទេស បញ្ហាគុណភាពសេវា លទ្ធភាពធនធានហិរញ្ញវត្ថុ និងជាពិសេសមិនទាន់មានការប្រើប្រាស់ថ្នាលជាតិរួមគ្នា។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវដំណើរការនៃរដ្ឋាភិបាលឌីជីថល ត្រូវឈរលើប្រព័ន្ធអភិបាលកិច្ចឯកភាព ដែលគ្រប់ក្រសួង ស្ថាប័នទាំងអស់ជាផ្នែកមួយនិងធ្វើអន្តរសកម្មទៅវិញទៅមកក្នុងប្រព័ន្ធនេះ។

ក្នុងការចូលរួមអនុវត្តនូវគោលនយោបាននេះ ក្រសួងព័ត៌មានបានបំពេញភារកិច្ច និងផ្តល់នូវកិច្ចសហការរៀបចំ ***សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន*** ក្នុងគោលដៅបង្ការ ទប់ស្កាត់ និង បង្ក្រាបបទល្មើសបច្ចេកវិទ្យា ***សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ***ដើម្បីកំណត់គោលការណ៍ និងយន្តការបង្ការ គ្រប់គ្រង និងឆ្លើយតបចំពោះការគំរាមកំហែងសន្តិសុខឌីជីថល និងឧប្បត្តិហេតុសន្តិសុខឌីជីថល និង***សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន*** ក្នុងគោលបំណងធានាដល់សាធារណជនគ្រប់រូបនូវសិទ្ធិសេរីភាពក្នុងការទទួលបានព័ត៌មានពីស្ថាប័នសាធារណៈ ស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងន័យនេះ ក្រសួងព័ត៌មាន នឹងបន្តកិច្ចសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីជំរុញដំណើរការបរិវត្តកម្មឌីជីថល ដោយត្រូវចាប់ផ្តើមពីការរៀបចំនូវហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិត ការរៀបចំមជ្ឈមណ្ឌលទិន្នន័យនិងប្រព័ន្ធក្លោដ ដែលមានលក្ខណៈសមាហរណកម្មស្របតាមអភិក្រមក្នុងទម្រង់ពាក់កណ្តាលវិមជ្ឈការ ជាដើម។ ជាមួយគ្នានេះដែរ ក្រសួងព័ត៌មាននឹងបន្តការរៀបចំប្រព័ន្ធអ៊ីម៉ែល វិបផតថលជាតិ ប្រព័ន្ធសហការរួម ប្រព័ន្ធផ្ញើសារ ប្រព័ន្ធគ្រប់គ្រងឯកសារ និងជាពិសេស ការរៀបចំកម្មវិធីបណ្តុះបណ្តាល កម្មវិធីបញ្ជ្រាបការយល់ដឹងនិងការអប់រំអំពីចំណេះដឹងមូលដ្ឋានបច្ចេកវិទ្យាឌីជីថល និងការប្រើប្រាស់សេវាសាធារណៈឌីជីថល។

## *ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជាឆ្នាំ២០២១-២០៣៥*

ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ២០២១-២០៣៥ បានដាក់ចេញនូវចក្ខុវិស័យវែងឆ្ងាយក្នុងការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំនូវមូលដ្ឋានគ្រឹះសម្រាប់ការទទួលយក និងការធ្វើបរិវត្តកម្មឌីជីថលទៅគ្រប់តួអង្គ និងតាមក្រសួង ស្ថាប័ន ដើម្បីរួមចំណែកជំរុញសន្ទុះកំណើនថ្មី និងលើកកម្ពស់សុខុមាលភាពសង្គម តាមគន្លងប្រក្រតីភាពថ្មី។

ក្នុងន័យនេះ ក្រសួងព័ត៌មានបានត្រៀមខ្លួនក្នុងការកសាងសង្គមឌីជីថល ដោយផ្តោតលើការរួមចំណែកធ្វើបរិវត្តកម្មឌីជីថលក្នុងវិស័យការងារ តាមរយៈការរៀបចំហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ដំណើរការបរិវត្តកម្មឌីជីថល (ការតភ្ជាប់ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា...) បង្កើនភាពជឿជាក់លើប្រព័ន្ធឌីជីថល ការបណ្តុះទេពកោសល្យឌីជីថល រៀបចំការគ្រប់គ្រងទិន្នន័យនិងស្ថិតិបែបឌីជីថលក្នុងការងារព័ត៌មាន និងសោតទស្សន៍ និងការងាររដ្ឋបាលក្រសួង។ ដូចនេះ ការងារដែលត្រូវចូលរួមអនុវត្តជាបន្ត ដើម្បីអភិវឌ្ឍវិស័យព័ត៌មាន និងសោតទស្សន៍ រួមមាន៖

- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ (ការតភ្ជាប់ឌីជីថល)៖ ***ចូលរួមកសាងច្បាប់ និងបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងធនធានវិសាលគមន៍វិទ្យុ***
- បង្កើនទំនុកចិត្តនិងភាពជឿជាក់លើប្រព័ន្ធឌីជីថល(***ជំរុញការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរួម***)
- ចូលរួមក្នុងការរៀបចំកសាងច្បាប់ និងបទដ្ឋានគតិយុត្ត ជាអាទិ៍ ***ច្បាប់ស្តីពីការការពារទិន្នន័យនិងឯកជនភាព ច្បាប់ស្តីពីព័ត៌មានសាធារណៈ ច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ច្បាប់ស្តីពីអាថ៌កំបាំងពាណិជ្ជកម្មនិងព័ត៌មានដែលមិនអាចបង្ហាញចេញ***
- រួមចំណែកក្នុងដំណើរការធ្វើវិសោធនកម្ម ឬកែសម្រួល បន្តរៀបចំលើ***បទដ្ឋានគតិយុត្តពាក់ព័ន្ធសន្តិសុខសាយប័រ*** *ដើម្បីឆ្លើយតបនឹងបរិការណ៍ថ្មី និងស្ថានភាពជាក់ស្តែង*

- ចូលរួមរៀបចំយន្តការឆ្លើយតបទៅនឹងឧប្បត្តិហេតុសន្តិសុខកំព្យូទ័រ និងអ៊ីនធឺណិត ដើម្បីជាបង្គោលក្នុងការផ្លាស់ប្តូរព័ត៌មានពីបញ្ហា និងឯហានិភ័យផ្សេងៗ
- ផ្តល់កិច្ចសហការរៀបចំ ***យុទ្ធសាស្ត្រ និងគោលការណ៍ណែនាំ*** ដើម្បីលើកកម្ពស់ការយល់ដឹងពីបញ្ហាសន្តិសុខសាយប័រតាមកម្រិត។

### ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០២៤-២០២៨***

ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) បច្ចុប្បន្នកម្មចាប់ពីឆ្នាំ២០២៤ ដល់២០២៨ ក្នុងក្របខ័ណ្ឌនៃទស្សនវិស័យនេះ និងផ្អែកតាមកម្មវិធីនយោបាយសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា រាជរដ្ឋាភិបាលដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព ដោយបន្តផ្តោតជាសំខាន់លើរបៀបវារៈជានា «ប្រសិទ្ធភាពសមិទ្ធកម្ម» តាមរយៈការអនុវត្តអភិក្រម «***ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់***» និងអភិក្រម «***ជវភាពនៃប្រព័ន្ធតួអង្គតែមួយ***»។ ទន្ទឹមនេះ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ កំណត់យកអាទិភាពគន្លឹះ៥ គឺៈ «***មនុស្ស ផ្លូវ ទឹក ភ្លើង និង បច្ចេកវិទ្យា***» ជាពិសេសគឺ «***បច្ចេកវិទ្យាឌីជីថល***» សម្រាប់ឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្ម៤.០ និងបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ច និងសង្គមកម្ពុជា ព្រមទាំងតម្រូវការក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ចដែលជាគ្រឹះ និងមធ្យោបាយដ៏សំខាន់ នៃការសម្រេចបានចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។ គោលដៅចម្បង នៃយុទ្ធសាស្ត្រនេះគឺ រក្សាសុខសន្តិភាព ស្ថេរភាព កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍជារួម ទន្ទឹមនឹងការកសាង និងពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ជំរុញសន្ទុះនៃការអភិវឌ្ឍប្រទេសជាតិ តាមរយៈការកសាងភាពធន់ នៃវិស័យទាំង៥ រួមមានៈ វិស័យសាធារណៈ វិស័យសេដ្ឋកិច្ច វិស័យហិរញ្ញវត្ថុ វិស័យមូលធនមនុស្សនិងសង្គម និងវិស័យបរិស្ថាននិងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា តាមរយៈយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ បញ្ចកោណទី៥ «***ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមឌីជីថល***» មុំទី១ «***ការកសាងរដ្ឋាភិបាលឌីជីថល និងពលរដ្ឋឌីជីថល***» ក៏បានកំណត់នូវការរួមចំណែកបន្ថែមពីវិស័យព័ត៌មាន និងសោតទស្សន៍ផងដែរ។ ក្នុងន័យនេះ ក្រសួងព័ត៌មានបានដាក់ចេញនូវអាទិភាពចំនួន៥ ដើម្បីដំណើរការការងារឱ្យមានប្រសិទ្ធភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ឆ្នាំ២០២៤-២០២៨ ដូចខាងក្រោមៈ

១. ការធ្វើទំនើបកម្មស្ថាប័ន និងការកសាងរដ្ឋបាលទំនើប
២. ការពង្រឹងបទដ្ឋានបច្ចេកទេស និងការទទួលខុសត្រូវវិជ្ជាជីវៈ
៣. ការអភិវឌ្ឍធនធានមនុស្សនិងបណ្តុះស្មារតីមនសិការវិជ្ជាជីវៈ
៤. ការរៀបចំប្រព័ន្ធនិងយន្តការគ្រប់គ្រងលំហាព័ត៌មាន និង
៥. ការបង្កើនភាពជាដៃគូប្រកបដោយបរិយាប័ន្ន និងស័ក្តិសិទ្ធភាព។

### ***ផែនការមេឌីជីថលអាស៊ានឆ្នាំ២០២៥***

ក្នុងការអនុវត្តគោលនយោបាយការបរទេសប្រកបដោយភាពបត់បែន វាងវៃ ឆ្លើយតបទៅនឹងសម្ពាធភូមិសាស្ត្រនយោបាយ និងការប្រកួតប្រជែងដ៏តានតឹងរបស់មហាអំណាចនានា កម្ពុជាបានធ្វើ

កិច្ចសហប្រតិបត្តិការយ៉ាងសកម្មជាមួយរដ្ឋសមាជិកអាស៊ានទាំងអស់ ដើម្បីសម្រេចបាននូវគោលដៅអាស៊ានជាសហគមន៍តែមួយ ដែលផ្អែកលើវិធានការច្បាប់ ដោយយកចិត្តទុកដាក់លើប្រជាជន និងយកប្រជាជនជាស្នូល ស្របតាម «*ទស្សនវិស័យតែមួយ អត្តសញ្ញាណតែមួយ សហគមន៍តែមួយ*» ព្រមទាំងជំរុញនិងលើកកម្ពស់ភាពជាដៃគូរបស់អាស៊ានជាមួយបណ្តាប្រទេស និងអង្គការតំបន់ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍អព្យាក្រឹត្យ ការមិនរើសអើង ការបើកចំហរ តម្លាភាព បរិយាប័ន្ន ការសម្លឹងឆ្ពោះទៅខាងក្រៅ ជាដើម។

ក្នុងន័យនេះ កម្ពុជាត្រៀមខ្លួនធ្វើការរួមគ្នាជាមួយរដ្ឋសមាជិកអាស៊ាន និងដៃគូអភិវឌ្ឍទាំងអស់ដើម្បីប្រែក្លាយអាស៊ាន ទៅជាសហគមន៍ឌីជីថល និងប្លុកសេដ្ឋកិច្ចមួយឈានមុខគេ ដែលជំរុញកំណើនសេដ្ឋកិច្ចដោយប្រើបច្ចេកវិទ្យា និងប្រព័ន្ធឌីជីថលប្រកបដោយសុវត្ថិភាព។ សម្រាប់ក្រសួងព័ត៌មាន ការងារមួយចំនួនដែលត្រូវធ្វើ រួមមាន៖

- ជំរុញកិច្ចសហប្រតិបត្តិការ និងកិច្ចព្រមព្រៀងក្នុងការរៀបចំយន្តការដើម្បីលើកកម្ពស់លទ្ធភាពទទួលបានព័ត៌មានឱ្យកាន់តែទូលំទូលាយ ប្រកបដោយគុណភាពនិងភាពជឿទុកចិត្តបាន
- លើកទឹកចិត្តដល់ការអភិវឌ្ឍកម្មវិធី និងការផ្សព្វផ្សាយព័ត៌មាន
- ការប្រើប្រាស់ព័ត៌មាន និងបច្ចេកវិទ្យាទំនាក់ទំនងក្នុងបរិបទឌីជីថល
- បង្កើតទំនាក់ទំនងរវាងអ្នកជំនាញសារព័ត៌មាន អ្នកស្រាវជ្រាវ ពាណិជ្ជករ/អាជីវករ និងប្រតិបត្តិករផ្សេងទៀតដើម្បីលើកកម្ពស់ការអភិវឌ្ឍវិស័យព័ត៌មាន។

## ២. ចក្ខុវិស័យ

ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពលើយន្តការផ្សព្វផ្សាយ ក្នុងបរិបទប្រែប្រួលនៃនិម្មាបនកម្ម និងរចនាសម្ព័ន្ធសណ្តាប់ធ្នាប់អន្តរជាតិ និងឆ្លុះបញ្ចាំងកម្ពុជាក្នុងមូលដ្ឋានឆ្ពោះទៅសម្រេច «*ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០*» ក្រសួងព័ត៌មានបានកំណត់នូវចក្ខុវិស័យដើម្បីតម្រង់ទិស និងប្រែក្លាយជា «*ស្ថាប័នទំនាក់ទំនងសាធារណៈរបស់រាជរដ្ឋាភិបាលប្រកបដោយបុរេសកម្ម សកម្ម អន្តរសកម្ម ប្រសិទ្ធភាព និងប្រសិទ្ធផល*» ដើម្បីគ្រប់គ្រងលំហព័ត៌មាន និងសហការធានាសន្តិសុខព័ត៌មាន។

## ៣. បេសកកម្ម

ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ ក្រសួងព័ត៌មានបានកំណត់បេសកកម្មជាចម្បងគឺ «*ការរៀបចំប្រព័ន្ធនិងយន្តការគ្រប់គ្រងព័ត៌មានលំហព័ត៌មាន*» ឱ្យមានភាពសុក្រឹត្យនិងប្រសិទ្ធភាព ដើម្បីធានាឱ្យបាននូវការគ្រប់គ្រងសន្តិសុខព័ត៌មាន ដោយត្រូវកំណត់នូវ៖

- *ក្របខណ្ឌគោលនយោបាយ* រួមមានការរៀបចំគោលនយោបាយជាតិស្តីពីព័ត៌មាននិងការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ និងការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យព័ត៌មាន និងផែនការសកម្មភាព
- *ក្របខណ្ឌច្បាប់និងបទដ្ឋានគតិយុត្ត* ដែលផ្តោតលើការរៀបចំបទដ្ឋានច្បាប់ ដែលពាក់ព័ន្ធនឹងវិស័យព័ត៌មាន លិខិតបទដ្ឋានគតិយុត្តផ្សេងៗ និងការរៀបចំស្តង់ដាប្រតិបត្តិ និងអនុលោមភាពនៃច្បាប់
- *ក្របខណ្ឌប្រតិបត្តិការ* ដោយត្រូវ៖

- ជានាលើទំនាក់ទំនងសាធារណៈរបស់រាជរដ្ឋាភិបាល ជាពិសេសជាមួយដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជន
- ពង្រឹងប្រសិទ្ធភាពស្ថាប័នលើការអនុវត្តបច្ចេកទេស និងកិច្ចការរដ្ឋបាល
- បង្កើនប្រសិទ្ធភាពគ្រប់គ្រង និងលើកកម្ពស់សេរីភាពព័ត៌មាន
- រក្សាសណ្ដាប់ធ្នាប់សារព័ត៌មាន
- លើកកម្ពស់គុណភាពព័ត៌មាន និងប្រព័ន្ធ/បណ្ដាញផ្សព្វផ្សាយ
- បន្តកសាងជំនឿទុកចិត្ត និងបន្សាបព័ត៌មានក្លែងក្លាយ។

## ៤. គោលដៅ គោលបំណង និងគុណតម្លៃ

### ៤.១. គោលដៅ

គោលដៅចម្បងនៃផែនការយុទ្ធសាស្ត្រ គឺការរៀបចំប្រព័ន្ធការងារដើម្បី «*ពង្រឹងនិងលើកកម្ពស់សមត្ថភាពស្ថាប័ន និងពង្រីកការធ្វើសមាហរណកម្មលើការគ្រប់គ្រងលំហព័ត៌មាន*»។

### ៤.២. គោលបំណង

គោលបំណង នៃផែនការយុទ្ធសាស្ត្រនេះ គឺបង្កើនប្រសិទ្ធភាពការងារ តម្លាភាព គណនេយ្យភាព និងសុខដុមនីយកម្ម ដើម្បីផ្ដល់សេវា «*ថ្មី ពិត លឿន និងទូលំទូលាយ ប្រកបដោយជំនឿទុកចិត្តនិងវិជ្ជាជីវៈ ដើម្បីផ្សារភ្ជាប់គ្រប់មជ្ឈដ្ឋាន*» ឈរលើគោលការណ៍ជាមូលដ្ឋាននៃភាពជាអ្នកដឹកនាំប្រសិទ្ធភាពស្ថាប័ននិងគុណភាពការងារ មូលធនមនុស្ស ពង្រឹងការអនុវត្តច្បាប់ និងកិច្ចសហប្រតិបត្តិការ។

### ៤.៣. គុណតម្លៃ

ទន្ទឹមនេះ គុណតម្លៃនៃការប្រតិបត្តិដើម្បីសម្រេចបាននូវចក្ខុវិស័យ បេសកកម្មនិងគោលដៅ និងគោលបំណងរបស់ក្រសួងព័ត៌មាន ត្រូវឈរលើកត្តាជាមូលដ្ឋាន ៥ រួមមាន៖

- *សុចរិតភាព* ជានាំនូវស្តង់ដាប្រតិបត្តិប្រកបដោយភាពស្មោះត្រង់ ជឿជាក់ ការផ្ដល់នូវតម្លៃ និងសីលធម៌ក្នុងការងារ ដើម្បីបង្កើនភាពរឹងមាំនៃស្ថាប័ន
- *ឧត្តមភាព* ការប្រើប្រាស់ចំណេះដឹង និងគំនិតច្នៃប្រឌិតឱ្យអស់ពីលទ្ធភាពនៅក្នុងការវិភាគ ការចូលរួម និងការធ្វើសេចក្ដីសម្រេចចិត្ត ដើម្បីភាពល្អប្រសើរខ្ពង់ខ្ពស់
- *ការចូលរួម* លើកទឹកចិត្តឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ដើម្បីធ្វើការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព និងការចែករំលែកបទពិសោធ និងចំណេះដឹងបានទូលំទូលាយ
- *គណនេយ្យភាព* លើកកម្ពស់ការទទួលខុសត្រូវចំពោះសកម្មភាព និងការសម្រេចចិត្តដែលបានអនុវត្តនៅក្នុងតួនាទី ភារកិច្ច និងដែនសមត្ថកិច្ចរបស់ខ្លួន និង
- *តម្លាភាព* បើកចំហព័ត៌មានជាសាធារណៈ និងការធ្វើសេចក្ដីសម្រេចចិត្ត ដើម្បីផលប្រយោជន៍រួម ដោយឆ្លុះបញ្ចាំងនូវគណនេយ្យភាពការងារសាធារណៈ។

# ៥. ក្របខណ្ឌយុទ្ធសាស្ត្រ

## ៥.១. ការវិភាគជាយុទ្ធសាស្ត្រ

ការអភិវឌ្ឍផ្នែកព័ត៌មាន និងសោតទស្សន៍ គឺអាស្រ័យលើនិន្នាការសំខាន់មួយចំនួនរួមមាននិន្នាការនយោបាយ ភូមិសាស្ត្រសេដ្ឋកិច្ច និងការវិវត្តផ្នែកបច្ចេកវិទ្យានិងឌីជីថល។ កត្តាទាំង ៣ នេះ បានជះឥទ្ធិពលខ្លាំងក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ និងទាមទារនូវការដាក់ចេញនូវយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ដើម្បីរក្សាលំនឹងស្ថានភាពសង្គម។

រាជរដ្ឋាភិបាលបានបង្ហាញច្បាស់អំពីចក្ខុវិស័យ និងគោលនយោបាយលើគ្រប់វិស័យដើម្បីបន្តការពារនិងកសាងកម្ពុជាទៅជាប្រទេសជឿនលឿនក្នុងតំបន់ ស្របតាមបំណងប្រាថ្នារបស់ប្រជាជនកម្ពុជា។ ក្នុងន័យនេះ ការរួមចំណែករក្សាឱ្យបាននូវសន្តិភាព ស្ថេរភាពនយោបនាយ តាមរយៈការគ្រប់គ្រងសណ្តាប់ធ្នាប់សារព័ត៌មាន លំហព័ត៌មាន និងសន្តិសុខព័ត៌មានជាអាទិភាពដ៏សំខាន់របស់ក្រសួងព័ត៌មានរួមជាមួយការពង្រឹងការងារការទូតព័ត៌មានក្នុងបរិបទនៃនិម្មាបនកម្មអន្តរជាតិ ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការតំបន់និងសកល ដែលផ្តល់ផលប្រយោជន៍គ្នាទៅវិញទៅមក និងផ្អែកលើមូលដ្ឋានច្បាប់។

មួយវិញទៀត ក្នុងដំណាក់កាលនៃនិម្មាបនកម្មសេដ្ឋកិច្ចសកលកំពុងប្រែប្រួលខ្លាំង ដោយមជ្ឈភាពនៃកំណើនសកលកំពុងបន្តនិន្នាការងាកមករកតំបន់អាស៊ី។ ក្នុងន័យនេះ កម្ពុជាគួរចាប់យកនូវឱកាសនេះ ដោយត្រូវជំរុញការផ្សព្វផ្សាយការតភ្ជាប់ប្រជាជននិងប្រជាជននៃបណ្តាប្រទេសក្នុងតំបន់ និងសកល។ ការរីកចម្រើនផ្នែកសេដ្ឋកិច្ច នឹងបន្តជំរុញវិល្បូរទំនិញ សេវា ពលកម្ម ការវិនិយោគ និងការផ្ទេរបច្ចេកវិទ្យា ដែលកត្តាទាំងនេះត្រូវការជាចាំបាច់នូវព័ត៌មានគ្រប់ជ្រុងជ្រោយ ដែលទុកចិត្តបានសម្រាប់ការសម្រេចចិត្ត។ ក្នុងបរិការណ៍នេះ ក្រសួងព័ត៌មាននឹងបង្កើនកម្រិតនៃកិច្ចសហប្រតិបត្តិការជាមួយសមភាគីទាំងក្នុងតំបន់ និងសកលលោកដើម្បីជំរុញបង្កើនការផ្សារភ្ជាប់កម្ពុជាជាមួយមជ្ឈដ្ឋានក្រៅ។

ទន្ទឹមនឹងនេះ ការរីកចម្រើនផ្នែកបច្ចេកវិទ្យាបាននាំមកនូវការប្រែប្រួលយ៉ាងឆាប់រហ័សក្នុងប្រព័ន្ធផ្សព្វផ្សាយ ពោលគឺប្រព័ន្ធផ្សព្វផ្សាយជំនាន់ថ្មី ដែលកំពុងជះឥទ្ធិពលខ្លាំងដល់វិស័យព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ។ ដើម្បីលើកកម្ពស់សមាហរណកម្មនៃវិស័យនេះ កម្ពុជាបាននិងកំពុងជំរុញការផ្លាស់ប្តូរការផ្សាយពីប្រព័ន្ធអាណាឡូកទៅប្រព័ន្ធឌីជីថល ស្របតាមការតាំងរួមរបស់អាស៊ាន និងត្រូវត្រៀមលក្ខណៈសម្រាប់ប្រព័ន្ធផ្សាយជំនាន់ថ្មី ដែលត្រូវបានប្រើប្រាស់ដើម្បីឱ្យការផ្សព្វផ្សាយកាន់តែប្រសើរ និងឆ្លើយតបចំពោះតម្រូវការបានល្អដើម្បីជំរុញការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយស្របតាមការវិវត្តនៃបច្ចេកវិទ្យា ដើម្បីលើកកម្ពស់ការអនុវត្តអភិក្រម «***ថ្មី ពិត លឿន និងទូលំទូលាយ ប្រកបដោយជំនឿទុកចិត្តនិងវិជ្ជាជីវៈ ដើម្បីផ្សារភ្ជាប់គ្រប់មជ្ឈដ្ឋាន***»។

## ៥.២. ទិសដៅយុទ្ធសាស្ត្រ

ដើម្បីជំរុញការដ្ឋានកំណែទម្រង់វិស័យព័ត៌មាន និងសោតទស្សន៍ឱ្យបានទទួលលទ្ធផលល្អប្រសើរ ក្រសួងព័ត៌មានបានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យព័ត៌មាន និងសោតទស្សន៍ ឆ្នាំ ២០២៤-២០២៨ ដោយបានកំណត់នូវទិសដៅយុទ្ធសាស្ត្រចំនួន ៥ គឺ៖

**ទី១.** កំណែទម្រង់ការគ្រប់គ្រងនិងដំណើរការការងាររដ្ឋបាល ដើម្បីធានានូវប្រសិទ្ធភាព និងគុណភាពការងារ

**ទី២.** កំណត់បទដ្ឋានច្បាប់/ គតិយុត្ត និងបទដ្ឋានបច្ចេកទេស ព្រមទាំងប្រព័ន្ធវាតយម្លៃការងារ

**ទី៣.** ការកសាង និងអភិវឌ្ឍសមត្ថភាពជំនាញគ្រប់គ្រង ដឹកនាំ និងជំនាញបច្ចេកទេស

**ទី៤.** គ្រប់គ្រងលំហព័ត៌មានប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពដោយផ្អែកលើមូលដ្ឋាននៃការផ្តល់ព័ត៌មានទូលំទូលាយនិងទាន់សភាពការណ៍ប្រកបដោយគុណភាព និងសុវត្ថិភាព និង

**ទី៥.** លើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូ ក្នុងក្របខណ្ឌទ្វេភាគីនិងពហុភាគីដើម្បីផលប្រយោជន៍រួម។

### ៥.៣. យុទ្ធសាស្ត្រ

ក្នុងការយកចិត្តទុកដាក់បន្តពង្រឹង និងពង្រីកសមិទ្ធផលនិងស្នាដៃនានា ដែលក្រសួងព័ត៌មានសម្រេចបានក្នុងនីតិកាលកន្លងមក និងស្ថិតក្នុងដំណាក់កាលនៃការបន្តជំរុញនូវកំណែទម្រង់ជានិរន្តរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងនីតិកាលទី៧ នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២៣-២០២៨ ក្រសួងព័ត៌មានបានធ្វើការប្រមូលផ្តុំ និងពិនិត្យឡើងវិញនូវរាល់បញ្ហាចម្បងៗ ដើម្បីដាក់ចេញនូវយុទ្ធសាស្ត្រអាទិភាពចំនួន៥ សម្រាប់រយៈពេល ៥ ឆ្នាំ ដែលជាក្របខណ្ឌអាទិភាព នៃការងារជាមូលដ្ឋានសម្រាប់ដំណើរការការដ្ឋានកំណែទម្រង់ដូចខាងក្រោម៖

១. ការធ្វើទំនើបកម្មស្ថាប័ននិងការកសាងរដ្ឋបាលទំនើប
២. ការពង្រឹងបទដ្ឋានបច្ចេកទេសនិងការទទួលខុសត្រូវវិជ្ជាជីវៈ
៣. ការអភិវឌ្ឍធនធានមនុស្សនិងបណ្តុះស្មារតីមនសិការវិជ្ជាជីវៈ
៤. ការរៀបចំប្រព័ន្ធនិងយន្តការគ្រប់គ្រងលំហព័ត៌មាន
៥. ការបង្កើនភាពជាដៃគូប្រកបដោយបរិយាប័ន្ននិងស័ក្តិសិទ្ធភាព។

## ៦. ផែនការសកម្មភាព

### ៦.១. ផែនការរយៈពេលខ្លី (ឆ្នាំ២០២៤)

ដើម្បីចូលរួមអនុវត្ត ឱ្យបានជោគជ័យនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងព័ត៌មាន បានបន្តយកចិត្តទុកដាក់ ដោយបានកំណត់នូវអាទិភាពការងារចម្បងៗចំនួន ៣ គឺ៖

**ក. ការពង្រឹងសមត្ថភាពនិងប្រសិទ្ធភាពស្ថាប័ន និងគុណភាពការងារ**

ក្នុងទិសដៅប្រែក្លាយជា **ស្ថាប័នសាធារណៈរបស់រាជរដ្ឋាភិបាល ប្រកបដោយបុរេសកម្ម សកម្ម អន្តរសកម្ម ប្រសិទ្ធភាព និងប្រសិទ្ធផល** ដើម្បីគ្រប់គ្រងសណ្តាប់ធ្នាប់សារព័ត៌មាន លំហព័ត៌មាន និងធានាបាននូវសន្តិសុខព័ត៌មាន ក្រសួងព័ត៌មានបានយកចិត្តទុកដាក់លើការពង្រឹងប្រសិទ្ធភាពស្ថាប័ន និងគុណភាពការងារជាចម្បងដោយត្រូវចាប់ផ្តើម៖

### ក.១. ការពង្រឹងសមត្ថភាពនិងប្រសិទ្ធភាពស្ថាប័ន

ការពង្រឹងសមត្ថភាពនិងប្រសិទ្ធភាពស្ថាប័ន គឺអាស្រ័យលើការដឹកនាំ និងរចនាសម្ព័ន្ធការងារច្បាស់លាស់។ ក្នុងន័យនេះ ក្រសួងព័ត៌មាននឹងដាក់ចេញនូវទិសដៅយុទ្ធសាស្ត្រ លើការធ្វើទំនើបកម្មស្ថាប័ន និងកសាងរដ្ឋបាលទំនើប ការពង្រឹងបទដ្ឋានបច្ចេកទេសនិងការទទួលខុសត្រូវវិជ្ជាជីវៈ និងការអភិវឌ្ឍធនធានមនុស្សនិងបណ្តុះស្មារតីមនសិការវិជ្ជាជីវៈ។

### ក.២. ការពង្រឹងគុណភាពការងារ

ការពង្រឹងគុណភាពការងារ ជាចលករក្នុងការលើកកម្ពស់ និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធការងារ ការគ្រប់គ្រង និងដំណើរការអនុវត្តប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល។ ក្នុងន័យនេះ ក្រសួងព័ត៌មានបាននិងកំពុងអនុវត្តៈ

- ***ការវិភាគមុខងារ*** ដោយធ្វើការពិនិត្យឡើងវិញលើរចនាសម្ព័ន្ធការងារ ទំហំការងារ តម្រូវការចំនួនមន្ត្រីតាមភារកិច្ចរបស់អង្គភាពនីមួយៗ ដើម្បីកាត់បន្ថយភាពត្រួតគ្នានៃភារកិច្ច និងការងារ។ ទន្ទឹមនេះដែរ ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ កសាងឯកសារមូលដ្ឋានសម្រាប់ការវិភាគមុខងារ និងពិពណ៌នាមុខតំណែងមន្ត្រីរាជការក្រសួងព័ត៌មាន។
- ***ការរៀបចំយន្តការជ្រើសរើសមន្ត្រី*** ដើម្បីលើកកម្ពស់គុណាធិបតេយ្យ និងឱកាសការងារជូនដល់អ្នកមានសមត្ថភាព តាមរយៈការកំណត់លក្ខខណ្ឌជ្រើសរើសមន្ត្រី និងយន្តការរៀបចំការប្រឡង ដោយនឹងស្នើសុំកិច្ចសហការពីក្រសួងមុខងារសាធារណៈ។ ក្នុងដំណើរការនេះ ក្រសួងព័ត៌មាន ធ្វើបច្ចុប្បន្នភាពស្ថិតិមន្ត្រីរាជការតាមជំនាញ ដោយពិនិត្យលើកម្រិតវប្បធម៌ ជំនាញបច្ចេកទេស បទពិសោធការងារ និងឆ្នាំដែលត្រូវចូលនិវត្តន៍ ដើម្បីរៀបចំផែនការធនធានមនុស្សសម្រាប់បន្តវេន និងអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រី បំពេញការងារប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាប័ន្ន និងប្រសិទ្ធភាពខ្ពស់
- ***ការរៀបចំប្រព័ន្ធលើកទឹកចិត្ត*** ដោយនឹងផ្តោតជាសំខាន់លើសមធម៌នៃការតែងតាំង ការបែងចែកប្រាក់រង្វាន់ពីសេវាសាធារណៈនិងការផ្តល់កិច្ចគាំពារដល់មន្ត្រីដែលជួបប្រទះបញ្ហាជីវភាព។ ដូចនេះ ក្រសួងនឹងកំណត់គោលការណ៍តែងតាំងនិងដំឡើងថ្នាក់ ដោយផ្អែកលើគុណវុឌ្ឍិនិងគុណសម្បត្តិ និងស្របតាមរចនាសម្ព័ន្ធមុខតំណែង ដោយអនុវត្តអភិក្រម «***អ្នកមានសមត្ថភាព ត្រូវបានលើកទឹកចិត្ត***»។

## ខ. ដំណើរការផ្លាស់ប្តូរប្រព័ន្ធផ្សាយទូរទស្សន៍ពីអាណាឡូកទៅឌីជីថល

### ខ.១. ការរៀបចំគោលនយោបាយជាតិ

ក្រសួងព័ត៌មាន នឹងរៀបចំគោលនយោបាយជាតិស្តីពីការផ្លាស់ប្តូរប្រព័ន្ធផ្សាយទូរទស្សន៍ពីប្រព័ន្ធអាណាឡូកទៅឌីជីថល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដោយផ្អែកលើផែនទីបង្ហាញផ្លូវសម្រាប់ការផ្លាស់ប្តូរប្រព័ន្ធផ្សាយទូរទស្សន៍ពីអាណាឡូកទៅឌីជីថល ឆ្នាំ២០១១។

### ខ.២. យន្តការគាំទ្រការផ្លាស់ប្តូរប្រព័ន្ធផ្សាយទូរទស្សន៍ទៅឌីជីថល

ក្រសួងព័ត៌មាននឹងរៀបចំយន្តការគាំទ្រការផ្លាស់ប្តូរប្រព័ន្ធផ្សាយទូរទស្សន៍ពីអាណាឡូកទៅឌីជីថល ដោយត្រូវ៖

- បន្តសហការ និងជំរុញឱ្យក្រុមហ៊ុនពន្លឿនការរៀបចំដាក់ដំណើរការថ្នាលទូរទស្សន៍ឌីជីថលកម្ពុជាត្រឹមាសទី២ ឆ្នាំ២០២៤ តាមផែនការ
- បំពេញបន្ថែមសេវាទូរទស្សន៍គ្រប់ប្រភេទ (ខ្សែកាបអ៊ុបទិក ផ្កាយរណប ប្រព័ន្ធអ៊ីនធឺណិត) ដើម្បីលើកកម្ពស់ការផ្សាយថ្នាលទូរទស្សន៍ឌីជីថល
- បិទប្រព័ន្ធផ្សាយទូរទស្សន៍អាណាឡូកនៅត្រឹមចុងឆ្នាំ ២០២៥ តាមការកំណត់របស់រាជរដ្ឋាភិបាល
- ផែនការអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់គ្រប់គ្រង និងប្រតិបត្តិការផ្សាយថ្នាលទូរទស្សន៍ឌីជីថល។

### ខ.៣. ការចូលរួមអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថល និងពលរដ្ឋឌីជីថល

ដើម្បីលើកកម្ពស់ទំនុកចិត្តប្រជាពលរដ្ឋ ចំពោះការផ្តល់សេវាសាធារណៈផ្នែកព័ត៌មាន និងសោតទស្សន៍ឱ្យកាន់តែល្អប្រសើរ តាមរយៈការអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ឆ្នាំ២០២២-២០៣៥ ដែលជាតួអង្គជំរុញកំណើនថ្មី ដើម្បីសម្រួលការគ្រប់គ្រង ដំណើរការអនុវត្ត និងការតាមដានលើការងារប្រកបដោយតម្លាភាព គណនេយ្យភាព និងសមធម៌។ គោលនយោបាយនេះបានកំណត់ដំណើរការបរិវត្តកម្មឌីជីថល ជាសសរស្តម្ភសម្រាប់ជំរុញការចាប់យកបច្ចេកវិទ្យាឌីជីថលប្រកបដោយភាពជឿទុកចិត្ត។ ក្នុងន័យនេះ ក្រសួងនឹងជំរុញការលើកកម្ពស់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល អភិបាលកិច្ចនិងសេវាសាធារណៈឌីជីថល ការកសាងសមត្ថភាពនិងនវានុវត្តន៍ឌីជីថល និងការលើកកម្ពស់កិច្ចសហការនិងភាពជាដៃគូរវាងរដ្ឋនិងឯកជនក្នុងការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយជីឌីថល។

## គ. ការគ្រប់គ្រងសណ្តាប់ធ្នាប់សារព័ត៌មាន

### គ.១ ការរៀបចំវិធានការច្បាប់/ បទដ្ឋានបច្ចេកទេស

បេសកកម្មជាចម្បងរបស់ក្រសួងព័ត៌មាន គឺ «*ការរៀបចំប្រព័ន្ធ និងយន្តការគ្រប់គ្រងព័ត៌មាននិងលំហាព័ត៌មាន*» ឱ្យមានភាពសុក្រឹត្យនិងប្រសិទ្ធភាព ដើម្បីធានាឱ្យបាននូវការរក្សាស្ថេរភាពព័ត៌មាន និងសន្តិសុខព័ត៌មាន និងបង្ការ ទប់ស្កាត់ព័ត៌មានក្លែងក្លាយ។ ក្នុងន័យនេះ ក្រសួងព័ត៌មាន បានពិនិត្យឡើងវិញលើការកសាងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ស្របតាមបរិបទនិងការវិវត្តនៃសង្គមដូចជា៖

- បន្តសហការជាមួយស្ថាប័នពាក់ព័ន្ធពិនិត្យលើសេចក្តីព្រាងដែលបានព្រាង

- ពិនិត្យនិងរៀបចំឡើងវិញច្បាប់ស្តីពីរបបសារព័ត៌មានដើម្បីឆ្លើយតបនឹងការវិវត្តនៃសង្គមជាតិ
- រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងព័ត៌មានក្លែងក្លាយ
- ធ្វើវិសោធនកម្មអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន លិខិតបទដ្ឋានពាក់ព័ន្ធនានា និងការរៀបចំឡើងនូវ «*ធម្មនុញ្ញសារព័ត៌មាន*» ដូចជានិយាមនីតិវិធីប្រតិបត្តិក្រមសីលធម៌សារព័ត៌មានដើម្បីពង្រឹងប្រសិទ្ធភាពស្ថាប័ននិងគុណភាពការងារជាដើម
- កំណត់ឡើងវិញចំពោះការផ្តល់អាជ្ញាបណ្ណ និងបណ្ណសម្គាល់អត្តសញ្ញាណអ្នកសារព័ត៌មាន ដែលចេញដោយក្រសួងព័ត៌មានតាមប្រព័ន្ធអនឡាញ និងភ្ជាប់ជាមួយ QR Code ផ្ទៀងផ្ទាត់ដោយសហការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធលើការរៀបចំសណ្តាប់ធ្នាប់ផ្សេងៗទៀតទាក់ទងនឹងនីតិវិធីប្រតិបត្តិការការងាររបស់អ្នកសារព័ត៌មានបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### គ.២. ការរៀបចំទិន្នន័យ និងស្ថិតិប្រព័ន្ធផ្សព្វផ្សាយ

- រៀបចំរបាយការណ៍ស្តីពីស្ថានភាព នៃសេរីភាពសារព័ត៌មាន នៅកម្ពុជា (របាយការណ៍ដំបូងក្នុងគោលបំណងឆ្លុះបញ្ចាំងពីស្ថានភាពនៃសេរីភាពសារព័ត៌មានកម្ពុជា និងការធ្វើបច្ចុប្បន្នភាពប្រព័ន្ធផ្សព្វផ្សាយ សេរីភាពសារព័ត៌មាននិងការស្ទង់មតិអ្នកសារព័ត៌មាននៅកម្ពុជាត្រូវបានចេញផ្សាយកាលពីខែមេសា ឆ្នាំ២០២៤)
- សិក្សាលើស្ថានភាពអាជីវកម្មព័ត៌មាន និងសោតទស្សន៍ ដែលកំពុងដំណើរការ ឬមិនដំណើរការ ដើម្បីមានវិធានការបន្ត
- រៀបចំបែបបទ និងនីតិវិធី ស្តីពីការស្នើសុំអាជ្ញាបណ្ណប្រកបអាជីវកម្មព័ត៌មាននិងសោតទស្សន៍ពីក្រសួងព័ត៌មាន។

## ៦.២. ផែនការរយៈពេលវែង (ឆ្នាំ២០២៤-២០២៨)

ដើម្បីសម្រេចបានចក្ខុវិស័យនៃការអភិវឌ្ឍវិស័យព័ត៌មាន និងសោតទស្សន៍ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្នុងទិសដៅនៃការធ្វើទំនើបកម្មស្ថាប័ននិងកសាងរដ្ឋបាល លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពព័ត៌មាន រក្សាសណ្តាប់ធ្នាប់សារព័ត៌មាន និងធានាបាននូវការគ្រប់គ្រងសន្តិសុខព័ត៌មាន ក្រសួងព័ត៌មានបានកំណត់នូវយុទ្ធសាស្ត្រជាអាទិភាពសំខាន់ចំនួន៥ ដែលបានឆ្លុះបញ្ចាំងពីគោលបំណង និងទិសដៅសម្រាប់រយៈពេល៥ឆ្នាំ (២០២៤-២០២៨)។

យុទ្ធសាស្ត្រទាំង៥ បានកំណត់នូវសកម្មភាព លទ្ធផលរំពឹងទុក រយៈពេលសម្រាប់អនុវត្តនិងអង្គភាពទទួលបន្ទុក/អនុវត្តដូចខាងក្រោម៖

## យុទ្ធសាស្ត្រទី១. ការធ្វើទំនើបកម្មស្ថាប័ននិងការ កសាងរដ្ឋបាលទំនើប

### ១.១. ទំនើបកម្មស្ថាប័ន

ដើម្បីសម្រេចបាននូវការលើកកម្ពស់សណ្តាប់ធ្នាប់ និងទីតាំងបំពេញភារកិច្ចស្នូល ការបង្កើនប្រសិទ្ធភាពការងារ ការរៀបចំការិយាល័យសមស្របសម្រាប់បំពេញការងារ ការលើកកម្ពស់ឧត្តមភាពក្នុងការបំពេញការងារ ការលើកកម្ពស់សិទ្ធិទទួលបានព័ត៌មាន ដំណើរការសាកល្បងរដ្ឋបាលឌីជីថល និងឌីជីថលូបនីយកម្មប្រព័ន្ធផ្សព្វផ្សាយ និងការលើកកម្ពស់ការគ្រប់គ្រងឯកសារ និងលិខិតស្នាមផ្សេងៗ ក្រសួងព័ត៌មានបានដាក់ចេញនូវទិសដៅ និងសកម្មភាពដូចខាងក្រោម៖

**ក. ទំនើបកម្មការិយាល័យការងារ**

- កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់សម្រួលដល់ការបំពេញការងារ
- ការកែលម្អអគារការិយាល័យ និងបំពាក់ឧបករណ៍ សម្ភារ បរិក្ខារជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ។

**ខ. លើកកម្ពស់សណ្តាប់ធ្នាប់ក្នុងបរិវេណក្រសួង**

- រៀបចំកែលម្អហេដ្ឋារចនាសម្ព័ន្ធការងារបរិវេណទីស្តីការក្រសួង។

**គ. បរិវត្តកម្មឌីជីថលប្រព័ន្ធផ្សព្វផ្សាយ**

- បង្កើនល្បឿន និងប្រសិទ្ធភាពនៃការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ
- រៀបចំមជ្ឈមណ្ឌលប្រព័ន្ធផ្សព្វផ្សាយចម្រុះតាមរលកវិទ្យុនិងប្រព័ន្ធអ៊ិនធឺណិត
- រៀបចំប្រព័ន្ធគ្រប់គ្រងឯកសារ និងលិខិតស្នាមផ្សេងៗ
- ធានានូវមធ្យោបាយ និងប្រព័ន្ធផ្នែកទន់សម្រាប់បំពេញការងារ
- ការចូលរួមអនុវត្តគោលនយោបាយរាជរដ្ឋាភិបាលឌីជីថល
- គាំទ្រការអនុវត្តការងារបរិវត្តកម្មឌីជីថលក្នុងក្របខណ្ឌក្រសួងព័ត៌មាន។

**ឃ. លើកកម្ពស់ប្រសិទ្ធភាព និងតម្លាភាពនៃការផ្តល់សេវាព័ត៌មាន និងសោតទស្សន៍**

- រៀបចំការផ្តល់សេវាប្រកបដោយគុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- លើកកម្ពស់ការអនុវត្តគោលការណ៍អភិបាលកិច្ចល្អ និងកម្មវិធីកែទម្រង់រដ្ឋបាលរបស់រាជរដ្ឋាភិបាល។

### ១.២. ការកែសម្រួលរចនាសម្ព័ន្ធ និងអភិវឌ្ឍសមត្ថភាពស្ថាប័ន

ដើម្បីសម្រេចបានរដ្ឋបាលឯកភាពក្នុងការងារដឹកនាំនិងគ្រប់គ្រង ការពង្រឹងប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពការងារក្នុងវិស័យព័ត៌មាន ការរៀបចំរចនាសម្ព័ន្ធការងារស្របតាមបរិបទនៃការអភិវឌ្ឍបច្ចេកវិទ្យា ការពង្រីកវិសាលភាពនៃការទទួលខុសត្រូវលើសន្តិសុខព័ត៌មាន ការបង្កើនសមត្ថភាពជំនាញលើការគ្រប់គ្រងលំហព័ត៌មាន ការកាត់បន្ថយការិយាធិបតេយ្យ ការពង្រឹងប្រសិទ្ធភាពការងារនិងពេលវេលា និងការបង្កើនការទទួលខុសត្រូវ គណនេយ្យភាព និងភាពម្ចាស់ការ ក្រសួងព័ត៌មានបានកំណត់នូវទិសដៅ និងសកម្មភាពដូចខាងក្រោម៖

**ក. ធ្វើបច្ចុប្បន្នភាពមុខងារ និងភារកិច្ចក្រសួងព័ត៌មានស្របតាមការវិវត្តនៃសង្គម និងការរីកចម្រើនផ្នែកបច្ចេកវិទ្យា**

- វិសោធនកម្មអនុក្រឹត្យស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗ។

**ខ. ការធានាដល់ដំណើរការប្រព្រឹត្តទៅរបស់ក្រសួងប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងបំពេញភារកិច្ចឱ្យសម្រេចបានលទ្ធផលល្អប្រសើរ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១**

- កំណត់ការបែងចែកភារកិច្ច ការទទួលខុសត្រូវ និងរបៀបរបបការងារដើម្បីកំណត់សមត្ថកិច្ចក្នុងការងារ ការទទួលខុសត្រូវនិងគណនេយ្យភាព និងតម្លាភាពក្នុងក្របខណ្ឌនៃការដឹកនាំ គ្រប់គ្រង និងប្រតិបត្តិការ។

**គ. ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងការងារ និងរដ្ឋបាលឌីជីថល**

- រៀបចំប្រព័ន្ធគ្រប់គ្រងដំណើរការរដ្ឋបាល
- រៀបចំឯកសារក្នុងទម្រង់ជាឌីជីថល
- កំណត់របៀបរបបនៃការតាក់តែងលិខិតរដ្ឋបាល និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ។

**ឃ. លើកកម្ពស់ការគ្រប់គ្រង ចរាចរ និងទុកដាក់ឯកសារនិងលិខិតស្នាម**

- រៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រង ចរាចរ និងទុកដាក់ឯកសារនិងលិខិតស្នាមនានា
- ធ្វើចំណាត់ថ្នាក់ប្រភេទឯកសារ ដើម្បីរក្សានិងការពារសុវត្ថិភាព និងងាយស្រួលស្វែងរក។

## ១.៣. កំណែទម្រង់ក្នុងវិស័យព័ត៌មាន និងសោតទស្សន៍

ក្នុងគោលបំណងចូលរួមក្នុងការដ្ឋានកំណែទម្រង់សំខាន់ៗទាំង៣ ក្រសួងព័ត៌មានបានដាក់ចេញនូវទិសដៅ សកម្មភាពការងា ដើម្បីសម្រេចបាននូវលទ្ធផលដែលបានកំណត់។

**ក. ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- រៀបចំការអនុវត្តសកម្មភាពសូចនាករសមិទ្ធកម្មគន្លឹះ ដែលរួមមាន៖
  - *គោលការណ៍ណែនាំហិរញ្ញវត្ថុសាធារណៈ (សៀវភៅមគ្គុទ្ទេសក៍គ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ប្រើប្រាស់ផ្ទៃក្នុងក្រសួងព័ត៌មាន)*
  - *ប្រាក់បេសកកម្ម (ក្នុងស្រុក ឬក្រៅប្រទេស) ត្រូវបើកតាមប្រព័ន្ធធនាគារ និងគោលការណ៍ណែនាំ*
  - *ចំនួនបណ្ណកម្មសិទ្ធិដីរដ្ឋត្រូវបានរៀបចំ*
  - *កំណត់លក្ខណៈវិនិច្ឆ័យនៃអង្គភាពថវិកា និងបង្កើនចំនួនអង្គភាពថវិកា (ផ្ទេរសិទ្ធពេញលេញ និងមិនពេញលេញ)*

- *របាយការណ៍ស្តីអំពីចំណាយបន្ទុកបុគ្គលិកដែលត្រូវបានញែកតាមកម្មវិធីនីមួយៗ តាមឆ្នាំគោល*
- *យន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃថវិកាសមិទ្ធកម្ម។*

- ពង្រឹងការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានហិរញ្ញវត្ថុ
  - *ប្រព័ន្ធរៀបចំផែនការសាច់ប្រាក់ (ព្យាករណ៍ចំណូល-ចំណាយ)*
  - *បន្តអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ*
  - *សាធារណៈ*
  - *ប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលមិនមែនសារពើពន្ធ*
  - *ប្រព័ន្ធផែនការយុទ្ធសាស្ត្រ និងគម្រោងចំណូល-ចំណាយ ប្រចាំឆ្នាំ*
  - *ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។*

## ខ. ការងារកែទម្រង់រដ្ឋបាលសាធារណៈ

- ការពិនិត្យឡើងវិញ ការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួង
  - *របាយការណ៍ស្តីពីការពិនិត្យឡើងវិញ ការវិភាគមុខងារ (បញ្ជីការងារ) និងរចនាសម្ព័ន្ធរួម*
  - *កម្មវិធីបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី*
  - *ផែនការពង្រាយមន្ត្រី។*
- បច្ចុប្បន្នភាពរចនាសម្ព័ន្ធនិងទិន្នន័យមន្ត្រីរាជការស៊ីវិលក្រសួង
  - *ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះឱ្យនាយកដ្ឋាន នៃអគ្គនាយកដ្ឋាននិងអង្គភាពជំនាញ*
  - *ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរព័ត៌មានរាជធានី ខេត្ត*
  - *របាយការណ៍បច្ចុប្បន្នភាពការគ្រប់គ្រងបុគ្គលិក និងវត្តមានមន្ត្រី*
  - *កាត់បន្ថយការិយាធិបតេយ្យ និងស្ទួនមុខងារ។*
- សិក្សាពីតម្រូវការសម្រាប់អនុវត្តការពង្រាយមន្ត្រី ដើម្បីលើកកម្ពស់ប្រសិទ្ធភាព គុណភាព និងសមិទ្ធកម្មការងារ
  - *រក្សាតុល្យភាពមន្ត្រីតាមអង្គភាពជំនាញស្របតាមតម្រូវការ និងបច្ចេកទេស។*

## គ. ការដឹកនាំកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ

- ពិនិត្យប្រសិទ្ធភាពការងារនិងមុខងារដែលបានផ្ទេរ
- រៀបចំសកម្មភាព និងតម្រូវការថវិកាបណ្តុះបណ្តាល
- រៀបចំបញ្ជីស្នើមុខងារសម្រាប់ធ្វើប្រតិភូកម្ម និងផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិ
  - *កំណត់មុខងារដែលត្រូវផ្ទេរ និងបញ្ជីតារាងសេវា*
  - *ការផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធភាព និងគុណភាព។*

## យុទ្ធសាស្ត្រទី២.ការពង្រឹងបទដ្ឋានច្បាប់និងបច្ចេកទេស និងការទទួលខុសត្រូវវិជ្ជាជីវៈ

### ២.១. ការរៀបចំបទដ្ឋានច្បាប់និងបទដ្ឋានគតិយុត្ត និងយន្តការលើកកម្ពស់ការអនុវត្ត

ក្នុងគោលដៅលើកកម្ពស់គុណភាព និងប្រសិទ្ធភាពការងារដឹកនាំនិងគ្រប់គ្រងវិស័យព័ត៌មាននិងសោតទស្សន៍ និងរក្សាបាននូវសណ្តាប់ធ្នាប់សារព័ត៌មាន ក្រសួងព័ត៌មានបានដាក់ចេញនូវទិសដៅការងារ៖

**ក. ពង្រឹងសមត្ថភាពស្ថាប័ន លើកកម្ពស់សណ្តាប់ធ្នាប់ និងការទទួលខុសត្រូវវិជ្ជាជីវៈ**

- កសាងបទដ្ឋានគតិយុត្តដើម្បីលើកកម្ពស់ការគ្រប់គ្រង
- បច្ចុប្បន្នភាពយន្តការនិងប្រព័ន្ធការងារ និងការលើកកម្ពស់ការអនុវត្តច្បាប់
- រៀបចំចងក្រង និងកំណត់គោលការណ៍ប្រតិបត្តិក្នុងវិស័យសារព័ត៌មាន។

ក្នុងន័យនេះ ក្រសួងបានរៀបចំនូវកម្មវិធីការងារកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តដូចខាងក្រោម៖

- *ច្បាប់ស្តីពីរបបសារព័ត៌មាន*
- *សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន*
- *សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងព័ត៌មានក្លែងក្លាយ*
- *សេចក្តីព្រាងច្បាប់ស្តីពីសោតទស្សន៍*
- *អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន*
- *អនុក្រឹត្យស្តីពីទិវាសារព័ត៌មានជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយសោតទស្សន៍*
- *អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីរបបសារព័ត៌មាន*
- *អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន*
- *អនុក្រឹត្យស្តីពីការអនុវត្តច្បាប់សោតទស្សន៍*
- *ជម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន*
- *គោលនយោបាយជាតិស្តីពីការអភិវឌ្ឍទូរទស្សន៍ឌីជីថល។*

**ខ. ពង្រឹងយន្តការលើកកម្ពស់ការអនុវត្ត**

- គណៈកម្មការប្រឆាំងព័ត៌មានក្លែងក្លាយ
  - *ត្រួតពិនិត្យការផ្សាយ និងតម្រង់ទិសជាយុទ្ធសាស្ត្រលើការប្រឆាំង ទប់ស្កាត់ និងលុបបំបាត់ព័ត៌មានក្លែងក្លាយ តាមគ្រប់មធ្យោបាយផ្សព្វផ្សាយ និងបណ្តាញទំនាក់ទំនងសង្គម*
  - *ចាត់វិធានការតាមផ្លូវច្បាប់ប្រឆាំងរាល់ព័ត៌មានក្លែងក្លាយ ដែលអាចបង្កមហន្តរាយដល់សន្តិសុខជាតិ ស្ថិរភាពនយោបាយ សុខដុមនីយកម្ម សណ្តាប់ធ្នាប់សង្គម និងកិត្យានុភាពជាតិ។*

- គណៈកម្មការតាមដាន វាយតម្លៃ និងលើកសរសើរការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មាន
    - *ពិនិត្យ វិនិច្ឆ័យ ដោះស្រាយលើសេចក្តីស្នើសុំ ឬបណ្តឹងតវ៉ាទាក់ទងនឹងក្រមសីលធម៌ វិជ្ជាជីវៈសារព័ត៌មានរវាងអ្នកសារព័ត៌មាន អង្គភាពសារព័ត៌មានជាមួយបុគ្គលឬក្រសួង ស្ថាប័ន ឬអ្នកសារព័ត៌មាន អង្គភាពសារព័ត៌មាន និងការតវ៉ាផ្សេងៗពីសាធារណជន ឬអង្គភាព ស្ថាប័ន។*
- គណៈកម្មការវាយតម្លៃ និងលើកសរសើរការអនុវត្តជម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន
    - *លើកកម្ពស់ការប្រតិបត្តិក្រមសីលធម៌សារព័ត៌មាន។*
- ក្រុមការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ និងគោលនយោបាយ
    - *ជំរុញការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពការងារ ផ្អែកលើអភិក្រម «**ពង្រឹង និងការរៀបចំផ្ទះរបស់ខ្លួនឱ្យរៀបរយ**»*
    - *សម្របសម្រួលរួម និងណែនាំដល់អង្គភាពចំណុះក្រសួង លើកិច្ចការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ និងគោលនយោបាយនានារបស់ក្រសួងព័ត៌មាន។*

## ២.២. លើកកម្ពស់សមត្ថភាពប្រព័ន្ធផ្សព្វផ្សាយ

### ក. ជំរុញការអភិវឌ្ឍមាតិកា និងខ្លឹមសារ

ដើម្បីលើកកម្ពស់គុណភាពព័ត៌មាន ការអភិវឌ្ឍមាតិកានិងខ្លឹមសារចាំបាច់ត្រូវយកចិត្តទុកដាក់ ដោយត្រូវរៀបចំគោលការណ៍ណែនាំស្តីពីការផលិតមាតិកា និងខ្លឹមសារដើម្បីធានាគុណភាព ប្រសិទ្ធភាពនិងសុក្រឹត្យភាពព័ត៌មាន ការប្រើប្រាស់បច្ចេកវិទ្យាថ្មីក្នុងការផលិតនិងផ្សាយនូវមាតិកាដើម្បីធ្វើឱ្យងាយស្រួលនិងមានប្រសិទ្ធភាពក្នុងការផ្តល់ព័ត៌មាន និងការបង្កើតមាតិកាដែលមានភាពច្នៃប្រឌិតប្រកបដោយទំនុកចិត្ត ភាពច្បាស់លាស់ និងគុណតម្លៃ។

ក្នុងន័យនេះ ក្រសួងព័ត៌មាននឹងត្រូវ៖

- រៀបចំគោលការណ៍ដើម្បីលើកកម្ពស់គុណភាពព័ត៌មាន ដោយផ្អែកលើមូលដ្ឋានបច្ចេកទេស និងបទដ្ឋានគតិយុត្ត
- ចូលរួមបណ្តុះបណ្តាលពង្រឹងសមត្ថភាពអ្នកសារព័ត៌មាន ដែលកំពុងអនុវត្តវិជ្ជាជីវៈរបស់ខ្លួន

### ខ. អភិវឌ្ឍបណ្តាញតភ្ជាប់

ដើម្បីបង្កើនសមត្ថភាពប្រព័ន្ធផ្សព្វផ្សាយ ការតភ្ជាប់ប្រព័ន្ធផ្សព្វផ្សាយនិងបណ្តាញសង្គមដើម្បីធានានូវការចូលរួមនិងការចែករំលែកព័ត៌មានប្រកបដោយប្រសិទ្ធភាព និងដើម្បីគ្រប់គ្រងការផ្សព្វផ្សាយដោយប្រសិទ្ធភាព ក្រសួងព័ត៌មាននឹង៖

- រៀបចំហេដ្ឋារចនាសម្ព័ន្ធដើម្បីលើកកម្ពស់សមត្ថភាព និងគ្រប់គ្រងការផ្សាយ។

- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីពង្រឹងការគ្របដណ្តប់សេវាប្រព័ន្ធអ៊ីនធឺណិតនៅតាមទីជនបទ ដើម្បីធានាថាប្រជាពលរដ្ឋនៅតាមតំបន់ដាច់ស្រយាលទទួលបានព័ត៌មានគ្រប់គ្រាន់

**គ. អភិវឌ្ឍសមត្ថភាព និងគុណភាពផ្សាយ**

ក្នុងគោលបំណងពង្រីកកម្រិតផ្សាយ និងតំបន់គ្របដណ្តប់បានទូលំទូលាយ ក្រសួងព័ត៌មាននឹង៖

- រៀបចំស្ថានីយ៍វិទ្យុផ្សាយបន្ត ម៉ាស៊ីនផ្សាយ និងកែលម្អស្ទូឌីយោវិទ្យុជាតិ អែហ្វអឹម និងឧបករណ៍បំពងសំឡេងចល័ត
- បង្កើនសមត្ថភាពស្ថានីយ៍ទូរទស្សន៍តំបន់ ដោយបំពាក់ឧបករណ៍និងសម្ភារបច្ចេកទេស
- បង្កើនថាមពលម៉ាស៊ីនផ្សាយវិទ្យុអាអឹម និងទំនើបកម្មឧបករណ៍ស្ទូឌីយោ
- រៀបចំរថយន្តថត-ផ្សាយចល័ត។

**ឃ. អភិរក្សប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី**

ដើម្បីរក្សាលំនឹង និងស្ថេរភាពនៃការផ្តល់ព័ត៌មានតាមគ្រប់ទម្រង់និងមធ្យោបាយ និងរក្សាឯកសារគ្រប់ប្រភេទនិងគ្រប់ទម្រង់ ក្រសួងព័ត៌មាននឹង៖

- រក្សានូវដំណើរការផ្សាយតាមរលកវិទ្យុ (តំបន់ជនបទ និងពុំមានសេវាអ៊ិនធឺណិតគ្របដណ្តប់)
- រក្សានូវដំណើរការចេញផ្សាយទស្សនាវដ្តី ព្រឹត្តិប័ត្រ និងការបោះពុម្ពផ្សេងៗ...
- រក្សាទុកនិងបង្ហាញឯកសារ និងវត្ថុតាងប្រវត្តិសាស្ត្រដែលពាក់ព័ន្ធនឹងប្រព័ន្ធផ្សព្វផ្សាយដូចជា ទូរទស្សន៍ វិទ្យុ សារព័ត៌មាន និងបណ្តាញ សង្គម
    - *សារមន្ទីរប្រព័ន្ធផ្សព្វផ្សាយជាតិ។*

## ២.៣. បង្កើតបណ្ណាសារអេឡិចត្រូនិក សម្រាប់រក្សាទុក និងគ្រប់គ្រងមាតិកាផ្សាយ

ក្នុងគោលបំណងការរក្សាទុកឯកសារប្រកបដោយសុវត្ថិភាព បង្កើតភាពងាយស្រួលក្នុងការស្វែងរកឯកសារមកប្រើប្រាស់ ធានាការបំប្លែងឯកសាពីផ្នែករឹងទៅផ្នែកទន់ និងរក្សាបាននូវនិរន្តរភាពនៃការគ្រប់គ្រងឯកសារគ្រប់ប្រភេទ ក្រសួងព័ត៌មាននឹង៖

**ក. រក្សាទុកទិន្នន័យរូបថត រូបភាព ហ្វីលឯកសារ វីដេអូ ឯកសារសំណេរ និងឯកសារសំឡេង**

- បំប្លែងទិន្នន័យគ្រប់ប្រភេទពីប្រព័ន្ធអាណាឡូកទៅឌីជីថល
- ការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យរូបថត រូបភាព ហ្វីលឯកសារ វីដេអូ ឯកសារសំណេរ និងឯកសារសំឡេង

**ខ. លើកកម្ពស់ការទុកដាក់ និងថែរក្សាឯកសារសម្រាប់ប្រើប្រាស់បន្ត និង ការសិក្សាស្រាវជ្រាវ**

**គ. រៀបចំ ប្រមូលផ្តុំ រក្សា គ្រប់គ្រងឯកសារ និងតភ្ជាប់ប្រព័ន្ធទៅមជ្ឈមណ្ឌលទិន្នន័យជាតិ**

**ឃ. ជំរុញបរិវត្តកម្មឌីជីថលក្នុងការគ្រប់គ្រងឯកសារ និងថែរក្សា**

បណ្តាចំណុច ខ. គ. និងឃ. ខាងលើ ក្រសួងព័ត៌មាននឹងផ្តោតការយកចិត្តទុកដាក់៖

- ឌីជីថលនីយកម្មឯកសារពីអាណាឡូក
- ឌីជីថលូបនីយកម្មប្រព័ន្ធថែរក្សានិងគ្រប់គ្រងឯកសារ និងលិខិតស្នាមរដ្ឋបាល។

## ២.៤. ការត្រៀមលក្ខណៈសម្រាប់ប្រព័ន្ធផ្សាយជំនាន់ថ្មី

ប្រព័ន្ធផ្សាយជំនាន់ថ្មី គឺជាប្រព័ន្ធដែលផ្តោតលើបច្ចេកវិទ្យាថ្មីៗ ដូចជាប្រព័ន្ធផ្សាយឌីជីថល និងបច្ចេកវិទ្យាផ្សេងៗ ដែលអាចផ្តល់ជូននូវគុណភាពខ្ពស់ជាងមុន។ ប្រព័ន្ធផ្សាយជំនាន់ថ្មីត្រូវបានប្រើប្រាស់ដើម្បីឱ្យការផ្សព្វផ្សាយកាន់តែប្រសើរ និងឆ្លើយតបចំពោះតម្រូវការបានល្អ។

ក្នុងការត្រៀមលក្ខណៈ ក្រសួងព័ត៌មាននឹងកំណត់ពីលទ្ធភាពដើម្បីជំរុញការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយស្របតាមការវិវត្តនៃបច្ចេកវិទ្យា ដើម្បីលើកកម្ពស់ការអនុវត្តអភិក្រម «***ថ្មី ពិត លឿន និងទូលំទូលាយ ប្រកបដោយជំនឿទុកចិត្តនិងវិជ្ជាជីវៈ ដើម្បីផ្សារភ្ជាប់គ្រប់មជ្ឈដ្ឋាន***»។ ក្នុងន័យនេះ ក្រសួងព័ត៌មាននឹង៖

**ក. រៀបចំកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជំនាញក្នុងក្របខណ្ឌតំបន់ និងទ្វេភាគីដើម្បីសិក្សារួមគ្នា និង**

**ខ. សិក្សា ស្រាវជ្រាវអំពីបញ្ញាសិប្បនិមិត្ត និងនវានុវត្តសម្រាប់ប្រព័ន្ធផ្សព្វផ្សាយ។**

# យុទ្ធសាស្ត្រទី៣. ការអភិវឌ្ឍធនធានមនុស្ស និងបណ្តុះស្មារតីមនសិការវិជ្ជាជីវៈ

## ៣.១. អភិវឌ្ឍធនធានមនុស្សក្នុងវិស័យព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ

ក្នុងទិសដៅពង្រឹងសមត្ថភាពស្ថាប័ន គុណភាពមន្ត្រី និងប្រសិទ្ធភាពការងារ ក្រសួងព័ត៌មាននឹងដាក់ចេញនូវទិសដៅការងារដើម្បីសម្រេចនូវគោលដៅ ដូចខាងក្រោម៖

**ក. បង្កើនសមត្ថភាពផ្នែកច្បាប់សម្រាប់ការគ្រប់គ្រងអង្គភាព**

- កំណត់លើការប្រគល់តួនាទីនិងភារកិច្ច និងការដំឡើងថ្នាក់និងឋានន្តរស័ក្តិដោយផ្អែកលើគុណាធិបតេយ្យ និង
- ធ្វើបច្ចុប្បន្នភាពបទបញ្ជាផ្ទៃក្នុងដើម្បីការលើកកម្ពស់ការបំពេញការងាររបស់មន្ត្រីរាជការ។

**ខ. កសាងសមត្ថភាពមន្ត្រីតាមជំនាញ និងបច្ចេកទេស**

- វាយតម្លៃ និងវិភាគមុខងារ ដើម្បីកំណត់ពីតម្រូវក្នុងការកសាងនិងអភិវឌ្ឍជំនាញ
- អនុវត្តកម្មវិធីបណ្តុះបណ្តាលមូលដ្ឋានលើជំនាញបច្ចេកទេស និង
- បច្ចុប្បន្នភាពស្ថិតិមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ និងទំហំការងាររបស់ក្រសួង។

**គ. លើកកម្ពស់សមត្ថភាពមន្ត្រីក្នុងការងារទំនាក់ទំនងសាធារណៈ**

- អភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញ និងបច្ចេកទេសលើការងារទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិ

**ឃ. កសាងសមត្ថភាពគ្រូបង្គោល និងកម្លាំងបន្តវេន**

- ផ្តល់នូវការបណ្តុះបណ្តាល ដើម្បីកសាងធនធានមនុស្ស និងអភិវឌ្ឍមូលធនមនុស្សស្របតាមការរីកចម្រើនផ្នែកបច្ចេកវិទ្យា និងការវិវត្តរបស់សង្គមជាតិ
- អនុវត្តកម្មវិធីបណ្តុះបណ្តាល និងបង្កើនសមត្ថភាពកម្លាំងសម្រាប់ជ្រើសរើសជាអ្នកបន្តវេន (ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង)។

**ង. រៀបចំកម្មវិធីកសាងនិងអភិវឌ្ឍធនធានមនុស្ស**

- កម្មវិធីបណ្តុះបណ្តាលមូលដ្ឋាន លើជំនាញបច្ចេកទេស
- ការបណ្តុះបណ្តាល ដើម្បីកសាងធនធានមនុស្ស និងអភិវឌ្ឍមូលធនមនុស្សស្របតាមការរីកចម្រើនផ្នែកបច្ចេកវិទ្យា និងការវិវត្តរបស់សង្គមជាតិ
- កសាង និងអភិវឌ្ឍសមត្ថភាពមន្ត្រីលើការងារទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- កម្មវិធីបណ្តុះបណ្តាល និងបង្កើនសមត្ថភាពកម្លាំងសម្រាប់ជ្រើសរើសជាអ្នកបន្តវេន
- ការរៀបចំអាហាររូបករណ៍សម្រាប់បន្តការសិក្សាតាមជំនាញ
- សហការជាមួយដៃគូរលើកម្មវិធី និងវគ្គបណ្តុះបណ្តាលបច្ចេកទេសជំនាញ (ព័ត៌មាន និងសោតទស្សន៍) រយៈពេលខ្លី មធ្យម និងវែង

**ច. ដាក់ឱ្យដំណើការឡើងវិញនូវការបណ្តុះបណ្តាលវិក្រឹត្យការវិជ្ជាជីវៈព័ត៌មាន**

- វគ្គបណ្តុះបណ្តាលប្រចាំឆ្នាំលើជំនាញ និងបច្ចេកទេសដល់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា

## ៣.២. ការបណ្តុះបណ្តាលស្មារតីទទួលខុសត្រូវ និងវិជ្ជាជីវៈ

ក្នុងគោលដៅលើកកម្ពស់ការគោរពវិន័យការងារ និងការទទួលខុសត្រូវឱ្យបានម៉ឺងម៉ាត់ ការពង្រឹងសមត្ថភាពចំណេះដឹងនិងជំនាញឌីជីថលក្នុងវិស័យព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយ និងការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញគ្រប់គ្រង និងភាពជាអ្នកដឹកនាំ ក្រសួងព័ត៌មាននឹងដាក់ចេញទិសដៅ និងសកម្មភាពការងារដូចខាងក្រោម៖

**ក. លើកកម្ពស់ និងពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ (ក្រុមប្រឹក្សាវិន័យក្រសួងនិងបទបញ្ជាផ្ទៃក្នុង និងការប្រឆាំងអំពើពុករលួយប្រចាំក្រសួង...)**

- ធានានិងពង្រឹងនូវដំណើការការងារប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ស័ក្តិសិទ្ធភាព ដើម្បីរក្សាសណ្តាប់ធ្នាប់ និងរបៀបរៀបរយការងារ និង
- កំណត់នូវលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃរបស់ក្រុមប្រឹក្សាវិន័យ។

**ខ. ការអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈ ដើម្បីអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន និងស្មារតីការងារសមូហភាព**

- អនុវត្តកម្មវិធីបណ្តុះបណ្តាលលើបច្ចេកទេសថ្មីៗ (ឌីជីថល...)

- កសាងនិងអភិវឌ្ឍសមត្ថភាពដឹកនាំ និងគ្រប់គ្រង
- លើកកម្ពស់សមត្ថភាពរៀបចំផែនការសកម្មភាព និងស្មារតីទទួលខុសត្រូវ ជំរុញការអនុវត្តច្បាប់ និង
- រៀបចំ និងដាក់ឱ្យដំណើការឡើងវិញនូវការបណ្តុះបណ្តាលវិក្រឹត្យការវិជ្ជាជីវៈសារព័ត៌មាន។

### ៣.៣. ការរៀបចំយន្តការលើកទឹកចិត្ត

ដើម្បីជំរុញការលើកទឹកចិត្តតាមរយៈផលប្រយោជន៍ដែលត្រូវទទួល លប់បំបាត់ករណីទំនាស់ផលប្រយោជន៍ក្នុងស្ថាប័ន បង្កើនការយកចិត្តទុកដាក់លើសុខុមាលភាពមន្ត្រី បង្កើននវានុវត្តន៍គុណភាពការងារនិងប្រកាន់ខ្ជាប់នូវសេចក្តីថ្លៃថ្នូរ អនុវត្តការបែងចែកផលប្រយោជន៍មន្ត្រី និងការគិតគូរអំពីកម្មវិធីមនុស្សធម៌ជូនដល់មន្ត្រី ក្រសួងព័ត៌មានមានទិសដៅ និងសកម្មភាព៖

#### ក. កិច្ចគាំពារមន្ត្រីក្រសួងព័ត៌មាន

- អត្ថប្រយោជន៍ និងសិទ្ធិត្រូវទទួលត្រូវបានជានា
- ផ្តល់ការលើកទឹកចិត្ត និងលប់បំបាត់នូវបញ្ហាទំនាស់ផលប្រយោជន៍
- ផ្តល់កិច្ចគាំពារស្ត្រី យុវជន និងកុមារ
- ការយកចិត្តទុកដាក់លើសុខុមាលភាព និងគ្រួសារមន្ត្រីរាជការ (ករណីសម្រាលបុត្រ រៀបការ និងមរណភាព)
- លើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យសារព័ត៌មាន និង
- ផ្តល់លទ្ធភាព និងលើកទឹកចិត្តជនមានពិការភាពក្នុងវិស័យសារព័ត៌មាន។

ទន្ទឹមនេះដែរ ផ្តល់នូវសមភាពក្នុងការតែងតាំង ការផ្តល់គ្រឿងឥស្សរិយយស និងការផ្តល់គ្រឿងឥស្សរិយយស ក្រសួងព័ត៌មានមានទិសដៅ និងសកម្មភាព៖

#### ខ. សុចរិតភាពនៃការតែងតាំង និងលើកទឹកចិត្តផ្អែកលើគុណាធិបតេយ្យ

- អនុវត្តជាប្រចាំការពិនិត្យ និងវាយតម្លៃលើគុណាធិបតេយ្យរបស់មន្ត្រីរាជការ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ និងគោលការណ៍ ដើម្បីស្នើសុំតែងតាំង
  - *បង្កើតគណៈកម្មការវាយតម្លៃគុណាធិបតេយ្យរបស់មន្ត្រីរាជការមុនទទួលបានការតែងតាំង*
  - *កំណត់លក្ខណៈវិនិច្ឆ័យ និងគោលការណ៍ ដើម្បីតែងតាំង*
- តំឡើងកាំប្រាក់តាមវេន សញ្ញាបត្រ និងការតាមការលើកទឹកចិត្ត និង
- ផ្តល់គ្រឿងឥស្សរិយយសតាមវេន និងការលើកទឹកចិត្ត។
  - *ការកំណត់លក្ខណៈវិនិច្ឆ័យ សម្រាប់ការផ្តល់គ្រឿងឥស្សរិយយស*
  - *បង្កើតគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិបេក្ខជន ដែលត្រូវស្នើសុំគ្រឿងឥស្សរិយយស។*

## យុទ្ធសាស្ត្រទី៤. ប្រព័ន្ធនិងយន្តការគ្រប់គ្រងលំហព័ត៌មាន

### ៤.១. យុទ្ធសាស្ត្រជាតិគ្រប់គ្រងព័ត៌មាន

ក្នុងគោលបំណងការពារសន្តិសុខព័ត៌មាននិងនិរន្តរភាពនៃការគ្រប់គ្រងព័ត៌មានធានាបាននូវសុចរិតភាព ការប្រើប្រាស់ឬទទួល និងការផ្សព្វផ្សាយឬចែករំលែកព័ត៌មានគ្រប់គ្រង និងការអភិវឌ្ឍប្រព័ន្ធព័ត៌មានក្នុងប្រទេស ដើម្បីធានាបាននូវការប្រើប្រាស់ទិន្នន័យនិងព័ត៌មានយ៉ាងមានប្រសិទ្ធភាព និងប្រកបដោយភាពជាក់ស្តែង ក្រសួងព័ត៌មានបានដាក់ចេញនូវទិសដៅ និងសកម្មភាព៖

**ក. គ្រប់គ្រងព័ត៌មាន និងការផ្សព្វផ្សាយទិន្នន័យពាក់ព័ន្ធសន្តិសុខ**

**ខ. គ្រប់គ្រងប្រសិទ្ធភាពនៃការផ្សព្វផ្សាយ**

**គ. លើកតម្កើងកិត្យានុភាពជាតិ ផ្អែកលើសមិទ្ធិផល និងស្នាដៃ**

**ឃ. គ្រប់គ្រងការផ្សាយក្នុងស្ថានភាពមានវិបត្តិ**

ទន្ទឹមនេះ ក្រសួងព័ត៌មាននឹងរៀបចំយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងព័ត៌មាន។

## ៤.២. គ្រប់គ្រងសន្តិសុខព័ត៌មាន

ក្នុងគោលបំណងរក្សានូវសណ្តាប់ធ្នាប់សារព័ត៌មាន និងជំរុញលើកកម្ពស់គុណភាពព័ត៌មាន ការទទួលបានព័ត៌មាន និងសុវត្ថិភាពព័ត៌មាន ក្រសួងព័ត៌មាននឹង៖

**ក. ធានា និងលើកកម្ពស់ការទទួលបានព័ត៌មាន គុណភាពព័ត៌មាន និងសុវត្ថិភាពព័ត៌មាន**

- ជំរុញការផ្សព្វផ្សាយព័ត៌មានតាមវិស័យការងារ
- ត្រួតពិនិត្យ តាមដាន និងដឹកនាំការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធបណ្តាញផ្សព្វផ្សាយព័ត៌មាន
- ជំរុញផ្តល់ព័ត៌មានគ្រប់ទម្រង់ អត្ថបទ រូបភាព វីដេអូ សម្លេង និងឯកសារផ្សេងៗ
- លើកកម្ពស់ការផ្សព្វផ្សាយតាមគ្រប់មធ្យោបាយ
- ការគ្រប់គ្រងការផ្សព្វផ្សាយព័ត៌មាន និងទិន្នន័យជាតិ
  - *ការកំណត់ចំណាត់ថ្នាក់ប្រភេទព័ត៌មានសម្រាប់ការផ្សព្វផ្សាយ*
  - *ព័ត៌មានត្រូវផ្តល់ដោយផ្អែកលើនីតិវិធី និងច្បាប់*
- លើកកម្ពស់ការផ្តល់នូវព័ត៌មានដែលត្រឹមត្រូវ និងមានប្រភពច្បាស់លាស់
- លើកកម្ពស់គុណភាពព័ត៌មានដោយផ្អែកលើភាពត្រឹមត្រូវ ភាពទាន់ពេលវេលា ភាពពេញលេញ ភាពជាក់ស្តែង/មិនលម្អៀង
- បង្កើតគោលការណ៍ណែនាំ និងពិធីសារស្តីពីការកសាងទំនាក់ទំនងរបស់ក្រសួងស្ថាប័នជាមួយប្រព័ន្ធផ្សព្វផ្សាយនិងអ្នកសារព័ត៌មាន ដើម្បីលើកកម្ពស់ការគ្រប់គ្រងនិងការផ្សព្វផ្សាយព័ត៌មានប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព និងអភិវឌ្ឍយុទ្ធសាស្ត្រឃោសនាបញ្ចុះបញ្ចូលសាធារណៈ
  - *ជំរុញការផ្សាយព័ត៌មាន និងការឃោសនា ដោយមានទឡ្ហីករណ៍លើកកម្ពស់រូបភាពវិជ្ជមាន និងកិត្យានុភាពក្រសួងស្ថាប័នជាតិ*

- *ជំរុញការផ្សាយអំពីសមិទ្ធផល និងអត្ថប្រយោជន៍ស្តែងចេញពីបេសកកម្ម ក្រសួងស្ថាប័នជាតិ គាំទ្រដល់ជីវភាព និងការរស់នៅរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យមានការផ្លាស់ប្តូរឥរិយាបថនិងភាពវិជ្ជមានក្នុងសង្គម*
- *ជំរុញការអនុវត្តគោលការណ៍ផ្សព្វផ្សាយដោយឈរលើមូលដ្ឋាននៃហេតុ ផលនិងទិសដៅ ដើម្បីកៀរគរមតិសាធារណៈ*
- *បណ្តុះស្មារតីមនសិកាទប់ទល់នឹងឥទ្ធិពលនៃការជ្រៀតជ្រែកពីបរទេស និងសកម្មភាពមានរបៀបវារៈនយោបាយ ដែលបំពុលលំហព័ត៌មានកម្ពុជា*

- ការកំណត់ពីការវាយតម្លៃលើកម្រិតសេរីភាពសារព័ត៌មាននៅកម្ពុជា
    - *របាយការណ៍ប្រចាំឆ្នាំស្តីពីសេរីភាពសារព័ត៌មាន។*

## ៤.៣. យុទ្ធនាការ «និយាយថាទេ ចំពោះព័ត៌មានក្លែងក្លាយ»

ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីព័ត៌មានក្លែងក្លាយ ក្នុងចំណោមក្រុមគោលដៅ ការផ្តល់ចំណេះដឹងពេញលេញអំពីអក្ខរកម្មព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយ និងឌីជីថល និង សិក្សាស្រាវជ្រាវពីប្រសិទ្ធភាពយុទ្ធនាការប្រឆាំងព័ត៌មានក្លែងក្លាយ ក្រសួងនឹងបង្កើនកិច្ចសហប្រតិបត្តការជាមួយក្រុមហ៊ុនបណ្តាញទំនាក់ទំនងសង្គម ភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការសង្គមស៊ីវិលដើម្បី៖

**ក. បង្កើនការយល់ដឹងយល់ដឹងរបស់សាធារណអំពីគ្រោះថ្នាក់ និងផលវិបាកនៃព័ត៌មានក្លែងក្លាយ**

- ផ្សព្វផ្សាយពីគ្រោះថ្នាក់ និងផលវិបាកដែលបានកើតចេញពីព័ត៌មានក្លែងក្លាយ តាមប្រព័ន្ធផ្សព្វផ្សាយគ្រប់ទម្រង់និងគ្រប់មធ្យោបាយ
- រៀបចំការប្រកួតប្រជែងផលិតវីដេអូខ្លី (រយៈពេលពី ២៥-៣០ វិនាទី) ស្តីពីគ្រោះថ្នាក់/ផលវិបាកនៃព័ត៌មានក្លែងក្លាយ ភ្ជាប់ជាមួយនឹងសារអំពាវនាវ ដើម្បីបញ្ចេញតាមបណ្តាញសង្គម
- រៀបចំបង្កើត និងចែកចាយសម្ភារឧបទេសសម្រាប់ការផ្សព្វផ្សាយអប់រំដូចជាកូនសៀវភៅ ខិត្តប័ណ្ណ និងវីដេអូអំពីរបៀបកំណត់អត្តសញ្ញាណ និងការប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្លែងក្លាយ និង
- រៀបចំ និងដាក់ឱ្យដំណើរការការចុះឈ្មោះដើម្បីក្លាយអ្នកស្ម័គ្រចិត្ត និង/ឬជាទូតសុច្ឆន្ទៈសម្រាប់យុទ្ធនាកា។

**ខ. លើកកម្ពស់អក្ខរកម្មព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយ និងឌីជីថលក្នុងចំណោម មន្ត្រី និងប្រជាពលរដ្ឋទូទៅ ជាពិសេសយុវវ័យ**

- កម្មវិធីបណ្តុះបណ្តាលស្តីពីអក្ខរកម្មព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយ និងឌីជីថល ជូនមន្ត្រីព័ត៌មានក្រសួង-ស្ថាប័ន រាជធានី-ខេត្ត និង
- រៀបចំវគ្គអក្ខរកម្មព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយដល់សិស្ស និស្សិត និងរៀបចំវេទិកាជាមួយក្រុមអ្នកមានប្រជាប្រិយភាព អ្នកមានឥទ្ធិពល អ្នកបង្កើតមាតិកាអនឡាញ។

**គ. កាត់បន្ថយចំនួនព័ត៌មានក្លែងក្លាយ (ប្រសិទ្ធភាពក្នុងការកាត់បន្ថយព័ត៌មានក្លែងក្លាយ)**

- រៀបចំប្រព័ន្ធរាយការណ៍ព័ត៌មានក្លែងក្លាយ
- រៀបចំប្រព័ន្ធសម្រាប់ផ្ទៀងផ្ទាត់ព័ត៌មានក្លែងក្លាយ
- ពង្រឹងសមត្ថភាពប្រព័ន្ធផ្សព្វផ្សាយក្នុងការស្រាវជ្រាវ ផ្ទៀងផ្ទាត់ និងបញ្ចេញព័ត៌មានពិតដើម្បីបន្សាបព័ត៌មានក្លែងក្លាយ
- ពង្រឹងសមត្ថភាពមន្ត្រីអ្នកនាំពាក្យតាមបណ្តារាជធានី-ខេត្ត
- បង្កើតក្រុមព័ត៌មាននិងឆ្លើយតបរហ័សប្រឆាំងព័ត៌មានក្លែងក្លាយ និង
- ចងក្រងក្រុមយុវវ័យស្ម័គ្រចិត្តប្រឆាំងព័ត៌មានក្លែងក្លាយក្រសួងព័ត៌មាន។

**ឃ. ពង្រឹងគុណភាពព័ត៌មាន និងលើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានពិត**

- សម្របសម្រួលការអនុវត្តយុទ្ធនាការក្នុង ២៥ រាជធានី-ខេត្ត ដោយសហការជាមួយមន្ទីរព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយ ក្រុមអ្នកមានឥទ្ធិពល អ្នកបង្កើតមាតិកាអនឡាញតាមបណ្តារាជធានី-ខេត្ត និង
- លើកកម្ពស់ភាពជាដៃគូក្នុងចំណោមប្រព័ន្ធផ្សព្វផ្សាយរដ្ឋ-ឯកជន ក្រុមអ្នកមានឥទ្ធិពលលើបណ្តាញសង្គម និងអ្នកបង្កើតមាតិកាអនឡាញ។

**ង. អប់រំស្តីពីច្បាប់ វិជ្ជាជីវៈព័ត៌មាន ក្រមសីលធម៌ មនសិកា ភាពជាគម្រូ និងការទទួលខុសត្រូវក្នុងសង្គម**

- ផ្តួចផ្តើមរៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់អ្នកសារព័ត៌មានវ័យក្មេង ដើម្បីផ្សព្វផ្សាយអំពីគ្រោះថ្នាក់នៃព័ត៌មានក្លែងក្លាយចំពោះយុវជន សង្គមទាំងមូល
- លើកទឹកចិត្តឱ្យមានការចូលរួមពីយុវជននៅកម្ពុជាក្នុងការប្រឆាំងនឹងព័ត៌មានក្លែងក្លាយ ព្រមទាំងចូលរួមផ្សព្វផ្សាយពីការពិតរបស់កម្ពុជាទៅដល់ប្រជាជននៅទូទាំងប្រទេស និងលើពិភពលោក។

**ច. ពង្រឹងកិច្ចសហប្រតិបត្តការរវាងស្ថាប័នរដ្ឋាភិបាល ក្រុមហ៊ុនបណ្តាញសង្គម និងសង្គមស៊ីវិល ដើម្បីប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ**

- ចូលរួមឱ្យបានសកម្ម និងអនុវត្តផែនការសកម្មភាពក្រុមការងារប្រឆាំងព័ត៌មានក្លែងក្លាយអាស៊ាន និង
- ចុះអនុស្សរណៈនៃការយោគយល់ជាមួយក្រុមហ៊ុនបណ្តាញទំនាក់ទំនងសង្គម និងសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលនានា ។

**ឆ. ស្រាវជ្រាវ និងបោះពុម្ពផ្សាយ**

- ស្ទង់មតិអំពីចំណេះដឹងសាធារណជនមុន និងក្រោយយុទ្ធនាការ
- រៀបចំចងក្រងរបាយការណ៍ និងបោះពុម្ពផ្សាយ។

## យុទ្ធសាស្ត្រទី៥. ការបង្កើនភាពជាដៃគូប្រកប ដោយបរិយាប័ន្ននិងស័ក្តិសិទ្ធភាព

### ៥.១. លើកកម្ពស់ប្រព័ន្ធនិងយន្តការតំបន់ និងអន្តរជាតិ (ថវិការអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់...)

ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការអនុតំបន់ តំបន់ (កាត់បន្ថយការបញ្ចេញមតិអវិជ្ជមាន និងទស្សនៈរំលោភបំពានមកលើគោលការណ៍នីតិរដ្ឋរបស់កម្ពុជា) ទទួលបានឱកាសនៃការផ្ទេរបច្ចេកវិទ្យានិងចំណេះដឹងថ្មីៗ ក្នុងវិស័យព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ និងឱកាសជំរុញសន្តិភាពនិងស្ថិរភាពតាមរយៈការរួមសហការ ដើម្បីដោះស្រាយបញ្ហាព័ត៌មានក្លែងក្លាយ ដើម្បីគ្រប់គ្រងការគំរាមកំហែង និងបំភ្លៃ បំផ្លើស និងកំភាន់ព័ត៌មាន ក្រសួងព័ត៌មានបានកំណត់ទិសដៅ និងសកម្មភាព៖

**ក. បង្កើនប្រសិទ្ធភាពការងារនិងកិច្ចសហប្រតិបត្តិការជាមួយដៃគូក្នុងវិស័យសារព័ត៌មាន**

- បង្កើនកិច្ចសហការជាមួយអង្គការ/ ដៃគូសារព័ត៌មានជាតិ និងអន្តរជាតិ ដើម្បីចែករំលែកបទពិសោធ និងចំណេះដឹង តាមរយៈកិច្ចព្រមព្រៀង អនុស្សរណៈកំណត់ទូត ជាដើម។

**ខ. សិក្សាពីគោលការណ៍ និងវិធានការបច្ចេកទេសដើម្បីការធ្វើសមាហរណកម្មក្នុងតំបន់ និងសកលលោក**

- លើកកម្ពស់សមត្ថភាពការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ
- រៀបចំមន្ត្រីបង្គោលសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគី និងជាមួយដៃគូ
- បច្ចុប្បន្នភាពគម្រោង និងកម្មវិធីកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ (ក្របខណ្ឌអន្តរក្រសួង អង្គការក្រៅរដ្ឋាភិបាល ដៃគូអភិវឌ្ឍ...)
- បន្តពង្រឹងទំនាក់ទំនងល្អជាមួយដៃគូយុទ្ធសាស្ត្រក្នុងតំបន់និងសកលលោកក្នុងទម្រង់ទ្វេភាគី/ ពហុភាគី។

## ៥.២. លើកកម្ពស់ការធ្វើសមាហរណកម្មវិស័យព័ត៌មាននិងសោតទស្សន៍ទៅក្នុងតំបន់ និងសកលលោក (ភាពព្វកិច្ច និងបដិភាគ....)

ដើម្បីបង្កើនសមាហរណកម្មវិស័យព័ត៌មាននិងសោតទស្សន៍ទៅក្នុងតំបន់ និងសកលលោក កសាងនិងលើកកម្ពស់សមត្ថភាពប្រជាពលរដ្ឋក្នុងប្រើប្រាស់ប្រព័ន្ធឌីជីថល ចែករំលែកព័ត៌មានបច្ចេកវិទ្យានិងចំណេះដឹង ពង្រឹងប្រព័ន្ធតភ្ជាប់រវាងប្រព័ន្ធជាតិនិងអន្តរជាតិ និងបង្កើនប្រសិទ្ធភាពព័ត៌មាននិងការលុបបំបាត់ព័ត៌មានក្លែងក្លាយ ក្រសួងព័ត៌មានបានកំណត់ទិសដៅ និងសកម្មភាព៖

**ក. ធ្វើទំនាក់ទំនងលើការផ្តល់ព័ត៌មានដល់សាធារណជនទូទៅ (រួមទាំងក្នុងតំបន់អាស៊ាន) ស្ត្រីនិងកុមារ ជនមានពិការភាព វិស័យសាធារណៈ វិស័យឯកជន សង្គមស៊ីវិល អ្នកមានឥទ្ធិពលក្នុងសង្គម និងប្រព័ន្ធផ្សព្វផ្សាយ**

- បង្កើនសមត្ថភាពនិងគុណភាពក្នុងតំបន់ និងជាសកលលើបច្ចេកទេសទាក់ទងនឹងវិស័យព័ត៌មាននិងសោតទស្សន៍
- បង្កើនការសហការជាមួយដៃគូអន្តរជាតិ ដើម្បីទទួលបានចំណេះដឹងថ្មីៗ និងបច្ចេកទេសដែលមានប្រសិទ្ធភាព
- បង្កើនការពិភាក្សាអំពីច្បាប់និងបទបញ្ញាដែលគ្រប់គ្រងវិស័យព័ត៌មាននិងសោតទស្សន៍ ដើម្បីធានាការគ្រប់គ្រងត្រឹមត្រូវ និងមានសុវត្ថិភាព។

**ខ. លើកកម្ពស់ការអនុវត្តផែនការយុទ្ធសាស្ត្រអាស៊ានស្តីពីព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ**

- ផ្តល់ការបណ្តុះបណ្តាល និងការចែករំលែកចំណេះដឹងដើម្បីបង្កើនសមត្ថភាព នៃវិស័យព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ
- ពង្រឹងការយល់ដឹង និងការចូលរួមរបស់ប្រជាជនក្នុងវិស័យ ព័ត៌មាន និង ប្រព័ន្ធផ្សព្វផ្សាយដើម្បីបង្កើនកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ាន
- ផ្សព្វផ្សាយការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ដើម្បីលើកកម្ពស់គុណភាពនៃ ព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយក្នុងតំបន់
- លើកទឹកចិត្តការបង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគី និងចម្រុះក្នុងវិស័យ ព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ
- អភិវឌ្ឍវិស័យព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយដោយអនុលោមតាមក្រម សីលធម៌ និងវិជ្ជាជីវៈ។

**គ. បង្កើត និងជំរុញកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិដើម្បីលើកកម្ពស់ការ ផ្សព្វផ្សាយនិងអភិវឌ្ឍន៍វិស័យសារព័ត៌មាន ទូរទស្សន៍ វិទ្យុ ...**

- បច្ចុប្បន្នភាពលើកិច្ចព្រមព្រៀង អនុស្សរណៈ ឬឯកសារនៃកិច្ចសហប្រតិបត្តិ ការផ្សេងៗ ដើម្បីពិនិត្យវឌ្ឍនភាព ឬតាមដានការអនុវត្តកន្លងមក
- ជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគីរបស់អគ្គនាយកដ្ឋាននីមួយៗ និងអង្គភាព ជំនាញ
- រៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ស្វែងរកកាគាំទ្រនៅក្រោម ក្របខណ្ឌអាស៊ាន ដៃគូទ្វេភាគី/ ពហុភាគី

**ឃ. ជំរុញកិច្ចសហប្រតិបត្តិការក្របខណ្ឌមេគង្គ**

ទន្ទឹមនេះដែរ ក្នុងគោលដៅជំរុញកិច្ចសហប្រតិបត្តិការក្របខណ្ឌមេគង្គ ក្រសួងព័ត៌មានបានផ្តោតជាសំខាន់លើការជំរុញៈ

- ជំរុញកិច្ចសហប្រតិបត្តិការមេគង្គ-ឡាងឆាង
  - *ជំរុញការអភិវឌ្ឍការតភ្ជាប់រវាងប្រជាជនកម្ពុជា-ចិន តាមរយៈការអភិវឌ្ឍ មូលដ្ឋានសារព័ត៌មាន និងការផ្សព្វផ្សាយ*
- លើកកម្ពស់កិច្ចសហប្រតិបត្តិការមេគង្គ-គង្គា
  - *លើកកម្ពស់កិច្ចសហប្រតិបត្តិការ និងជំរុញការផ្លាស់ប្តូរព័ត៌មានសង្គម និង វប្បធម៌*
- បង្កើនកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ
  - *រួមគ្នាផ្លាស់ប្តូរចំណេះដឹង វប្បធម៌ និងប្រពៃណីតាមប្រព័ន្ធផ្សព្វផ្សាយ។*

## ៥.៣. លើកកម្ពស់ការទូតព័ត៌មាន

យុទ្ធសាស្ត្រការទូត ជាផ្នែកមួយដ៏សំខាន់ក្នុងការបង្កើត និងរក្សាទំនាក់ទំនងជាមួយ ប្រទេសជាដៃគូឬអង្គការអន្តរជាតិ ដើម្បីផលប្រយោជន៍ជាតិ ដែលមានលក្ខណៈសេដ្ឋកិច្ច សង្គម សន្តិសុខ

ឬវប្បធម៌។ ដើម្បីចូលរួមអនុវត្តគោលនយោបាយការបរទេសរបស់រាជរដ្ឋាភិបាល ក្រសួងព័ត៌មានបានកំណត់ទិសដៅ និងសកម្មភាពដូចខាងក្រោម៖

**ក. គ្រប់គ្រងសាធារណមតិជាតិនិងអន្តរជាតិ ដើម្បីគាំទ្រនយោបាយការបរទេសក្នុងការលើកស្ទួយ និងការពារផលប្រយោជន៍ជាតិ**

- ធ្វើការវាយតម្លៃពីសេរីភាពសារព័ត៌មានកម្ពុជា ដើម្បីបញ្ជាក់ពីស្ថានភាពកម្ពុជាផ្អែកលើមូលដ្ឋាន «***មើលព្រៃទាំងមូល ប្រសើរជាងយកចិត្តទុកដាក់លើឈើមួយដើម***»
  - *របាយការណ៍ប្រចាំឆ្នាំស្ដីពីសេរីភាពសារព័ត៌មានកម្ពុជា*
- ផ្ដល់កិច្ចសហការផ្សព្វផ្សាយនយោបាយការបរទេសកម្ពុជា ដែលបម្រើលើកស្ទួយ និងការពារផលប្រយោជន៍ជាតិ
  - *បង្កើនកម្រិតផ្សព្វផ្សាយតាមរយៈយន្តការទូត។*

**ខ. បង្កើនការផ្សព្វផ្សាយពីកម្ពុជា ដើម្បីការពារឯករាជ្យ អធិបតេយ្យភាពជាតិ បូរណភាពទឹកដី អព្យាក្រឹត្យភាព រក្សាការពារឱ្យបានគង់វង្សនូវសន្តិភាព សន្តិសុខ ស្ថិរភាព សណ្ដាប់ធ្នាប់ និងឯកភាពសង្គម**

- បង្កើន និងបង្កើតកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នជំនាញដើម្បីផ្សព្វផ្សាយព័ត៌មាន និងព្រឹត្តិការណ៍នៅលើបណ្ដាញផ្សព្វផ្សាយរបស់ក្រសួងព័ត៌មាន
  - *សហការផលិត និងផ្សព្វផ្សាយព្រឹត្តិការណ៍ដំណឹង កម្មវិធី និងព័ត៌មានទាំងអត្ថបទ រូបថត រូបភាព វីដេអូនានាដើម្បីផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយ។*

**គ. រួមចំណែកជំរុញការងារការទូត តាមរយៈការផ្សព្វផ្សាយព័ត៌មានដែលផ្ដោតដល់ការលើកស្ទួយសេដ្ឋកិច្ច វប្បធម៌ និងទេសចរណ៍ នឹងរួមចំណែកដ៏សំខាន់មួយក្នុងការទាក់ទាញទុនវិនិយោគពីបរទេស ធ្វើពិពិធកម្មប្រភពវិនិយោគ**

- គ្រប់គ្រងសាធារណមតិអន្តរជាតិ
  - *បង្កើនការផ្សព្វផ្សាយព័ត៌មាន ដែលជួយកសាងរូបភាពជាតិជាវិជ្ជមាននៅក្រៅប្រទេស ដើម្បីលើកកម្ពស់មុខមាត់ វប្បធម៌ និងគោលនយោបាយរបស់កម្ពុជា*
- បង្កើតយន្តការគ្រប់គ្រងព័ត៌មានក្នុងករណីវិបត្តិជាយថាហេតុ
  - *ប្រព័ន្ធគ្រប់គ្រងព័ត៌មាន បង្កើតមាតិកា និងខ្លឹមសារ សម្រាប់គ្រប់គ្រងស្ថានការណ៍ក្នុងនិងក្រៅប្រទេស*
- ផ្សារភ្ជាប់ទំនាក់ទំនងប្រជាជននិងប្រជាជន តាមរយៈការផ្សព្វផ្សាយព័ត៌មានស្ដីពីវប្បធម៌ សិល្បៈ ទេសចរណ៍ជាដើម

- *ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដើម្បីបង្ហាញពីវប្បធម៌ តម្លៃ និងរបៀបរស់នៅ ដូចជាតាមរយៈភាពយន្ត កម្មវិធីទូរទស្សន៍ និងផលិតផលវប្បធម៌*

- ជំរុញការទូតព័ត៌មានឌីជីថល
  - *បង្កើនប្រតិបត្តិការផ្សព្វផ្សាយតាមបណ្ដាញសង្គម។*

**ឃ. បន្តពង្រឹងទំនាក់ទំនងមិត្តភាព សហប្រតិបត្តិការ និងភាពជាដៃគូក្នុងវិស័យការងារ និងពង្រឹង និងពង្រីកការតភ្ជាប់វិស័យព័ត៌មាន និងសោតទស្សន៍ក្នុងតំបន់ និងសកល**

- បច្ចុប្បន្នភាពលើគ្រប់កិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់ និងការអនុវត្តកំណត់ទូតនានា
  - *ទិន្នន័យកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងតំបន់ និងសកល។*

**ង. កសាងសមត្ថភាពទំនាក់ទំនងការបរទេសក្នុងជំនាញវិជ្ជាជីវៈ**

- បណ្ដុះបណ្ដាលទស្សនៈការទូត និងជំនាញចចារសម្រាប់ការងារកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌបច្ចេកទេសក្នុងវិស័យព័ត៌មាននិងសោតទស្សន៍
  - *វគ្គបណ្ដុះបណ្ដាលតួនាទីអ្នកសារព័ត៌មានក្នុងការងារការទូត/កិច្ចសហប្រតិបត្តិការអន្តរជាតិ។*

## ៥.៤. បង្កើតនិងជំរុញទំនាក់ទំនងជាមួយស្ថាប័នសារព័ត៌មានអន្តរជាតិ

ក្នុងគោលបំណងការពារកេរ្តិ៍ឈ្មោះ កិត្យានុភាព និងអធិបតេយ្យភាពកម្ពុជានៅលើឆាកអន្តរជាតិ បង្កើនការផ្សព្វផ្សាយដើម្បីការយល់ដឹងកាន់តែច្បាស់ពីកម្ពុជា បន្សាបនិងលប់បំបាត់ព័ត៌មានមិនពិត ព័ត៌មានក្លែងក្លាយ ព័ត៌មានមិនមានប្រភពច្បាស់លាស់ និងព័ត៌មានញុះញង់ និងបន្តកសាងនិងលើកកម្ពស់ទំនុកចិត្តនិងការជឿជាក់មកលើព្រះរាជាណាចក្រកម្ពុជា ក្រសួងព័ត៌មាន បានកំណត់ទិសដៅការងារ និងសកម្មភាពដូចខាងក្រោម៖

**ក. ផ្សព្វផ្សាយពីកម្ពុជាដើម្បីបង្ហាញពីជំហរ ការតាំងចិត្ត និងឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាល និងសមិទ្ធិផលនានា និងលើកកម្ពស់កិច្ចសហការក្នុងការផ្លាស់ប្ដូរព័ត៌មាន ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រង និងឆ្លើយតបសាធារណមតិ**

- ជំរុញការងារការទូតក្នុងវិស័យព័ត៌មាន និងកិច្ចសហប្រតិបត្តិការជាមួយស្ថានទូតនានា

**ខ. បង្កើតកិច្ចសហប្រតិបត្តិការបច្ចេកទេសតាមរយៈអនុស្សារណៈនិង/ឬកិច្ចព្រមព្រៀង**

- ស្នើសុំការភ្ជាប់ទំនាក់ទំនងជាមួយស្ថាប័នសារព័ត៌មានអន្តរជាតិ តាមរយៈស្ថានទូតប្រចាំកម្ពុជា

**គ. រៀបចំកម្មវិធីកសាង និងអភិវឌ្ឍសមត្ថភាពជំនាញក្រៅប្រទេសក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី (ជាពិសេសប្រទេសក្នុងក្របខណ្ឌអាស៊ាន +៣) និងពហុភាគី**

- ជំរុញមន្ត្រីជំនាញបច្ចេកទេសចូលរួមក្នុងវគ្គបណ្តុះបណ្តាល (ខ្លី មធ្យម វែង) សិក្ខាសាលា...។

## ៧. យន្តការដឹកនាំ និងអនុវត្ត

ការសម្រេចបាននូវចក្ខុវិស័យនៃការតម្រង់ទិស និងប្រែក្លាយក្រសួងព័ត៌មានជា «***ស្ថាប័នទំនាក់ទំនងសាធារណៈរបស់រាជរដ្ឋាភិបាល ប្រកបដោយបុរេសកម្ម សកម្ម អន្តរសកម្ម ប្រសិទ្ធភាព និងប្រសិទ្ធផល***» ដើម្បីគ្រប់គ្រងសណ្តាប់ធ្នាប់សារព័ត៌មាន លំហព័ត៌មាន និងធានាបាននូវសន្តិសុខព័ត៌មាន សុខដុមនីយកម្មសង្គម ក្រសួងព័ត៌មានបានកំណត់ពីការទទួលខុសត្រូវតាមឋានានុក្រមដឹកនាំ និងតាមតួនាទីនិងភារកិច្ច។ យន្តការនិងប្រព័ន្ធការងារក្រសួងត្រូវពង្រឹង ដើម្បីងាយស្រួលដល់ការជំរុញប្រតិបត្តិការការងាររបស់អគ្គនាយកដ្ឋានជំនាញ និងអង្គភាពជំនាញប្រកប ដោយការទទួលខុសត្រូវ និងឆ្លើយតបបេសកកម្មដែលបានកំណត់។

អនុកម្មវិធីនៃអង្គភាពថវិកា ក្រសួងព័ត៌មានត្រូវមានភាពជាម្ចាស់ក្នុងការគ្រប់គ្រងនិងដឹកនាំការងារ និងជាអង្គដ៏សំខាន់ក្នុងការជំរុញការអនុវត្តចង្កោមសកម្មភាព ដើម្បីឆ្លើយតបទៅនឹងគោលដៅរួមជាយុទ្ធសាស្ត្ររបស់ក្រសួង ក្នុងការសម្រេចឱ្យបានតាមដំណាក់កាល នៃសកម្មភាពដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រ។ អគ្គនាយកដ្ឋានជំនាញ/ អង្គភាពជំនាញចំណុះក្រសួងព័ត៌មាន ត្រូវយកចិត្តទុកដាក់រៀបចំផែនការសកម្មភាពតាមវិស័យរបស់ខ្លួន និងតម្រូវការថវិកាសម្រាប់រយៈពេល៥ ឆ្នាំ (ឆ្នាំ២០២៣-២០២៨)។ ផែនការសកម្មភាពត្រូវផ្សារភ្ជាប់ជាមួយទិសដៅអាទិភាពការងារនៃ (១). ការធ្វើទំនើបកម្មស្ថាប័ននិងការកសាងរដ្ឋបាលទំនើប (២). ការពង្រឹងបទដ្ឋានបច្ចេកទេសនិងការទទួលខុសត្រូវវិជ្ជាជីវៈ (៣). ការអភិវឌ្ឍធនធានមនុស្សនិងបណ្តុះស្មារតីមនសិការវិជ្ជាជីវៈ (៤). ការរៀបចំប្រព័ន្ធនិងយន្តការគ្រប់គ្រងលំហព័ត៌មាន និង (៥). ការបង្កើនភាពជាដៃគូប្រកបដោយបរិយាប័ន្ននិងស័ក្តិសិទ្ធភាព។

ទន្ទឹមនេះ គណៈកម្មាធិការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យព័ត៌មាន និងសោតទស្សន៍ (គ.គ.ផ.) របស់ក្រសួងព័ត៌មានដឹកនាំការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ដោយមានលេខាធិការដ្ឋាន ល.គ.គ.ផ. ជាជំនួយការ។

## ៨. ប្រភពថវិកា និងធនធានហិរញ្ញវត្ថុ

ដើម្បីជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យព័ត៌មាន និងសោតទស្សន៍ ឆ្នាំ២០២៤-២០២៨ ឱ្យមានប្រសិទ្ធភាព គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធត្រូវរៀបចំផែនការសកម្មភាព តាមដំណាក់កាល ដោយកំណត់ពីតម្រូវការថវិកាតាមឆ្នាំ។ គ.គ.ផ. និងអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុនឹងដឹកនាំពិនិត្យលើតម្រូវការថវិកា ដើម្បីរៀបចំយុទ្ធសាស្ត្រថវិកាតាមឆ្នាំ និងកម្មវិធីវិនិយោគសាធារណៈរបស់ក្រសួងព័ត៌មាន។

ក្រៅពីថវិកាជាតិ ក្រសួងផ្តល់នូវការគាំទ្រដល់គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ ក្នុងការរៀបចំគម្រោងសំណើរ ដើម្បីសុំការគាំទ្រផ្នែកហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងប្រភពស្របច្បាប់នានា។

## ៩. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ក្រុមការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ និងគោលនយោបាយរបស់ក្រសួងព័ត៌មាន (**ក.យ.ផ.គ.ពម**) ត្រូវបានបង្កើតដើម្បីជំរុញការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ និងសកម្មភាពការងារក្រសួង ដោយឈរលើអភិក្រម «***ពង្រឹង និងការរៀបចំផ្ទះរបស់ខ្លួនឱ្យរៀបរយ***» ដោយត្រូវសម្របសម្រួលរួម និងណែនាំដល់អង្គភាពចំណុះក្រសួង លើកិច្ចការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ និងគោលនយោបាយនានា របស់ក្រសួងព័ត៌មាន និងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨ ក្នុងក្របខ័ណ្ឌក្រសួងព័ត៌មាន។ ក.យ.ផ.គ.ពម ត្រូវរៀបចំសូចនាករសមិទ្ធកម្មគន្លឹះ សម្រាប់ការតាមដាន និងវាយតម្លៃការអនុវត្ត។

សន្និបាតបូកសរុបសមិទ្ធផលប្រចាំឆ្នាំការងារព័ត៌មាន និងសោតទស្សន៍ និងលើកទិសដៅការងារបន្តជាយន្តការពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាពរបស់អគ្គនាយកដ្ឋាន និងអង្គភាពជំនាញចំណុះឱ្យក្រសួង ដើម្បីឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យព័ត៌មាន និងសោតទស្សន៍ឆ្នាំ ២០២៤-២០២៨។

## ១០. សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យព័ត៌មាន និងសោតទស្សន៍ឆ្នាំ២០២៤-២០២៨ គឺជាផែនទីបង្ហាញផ្លូវ ដែលកំណត់ពីការឯកភាពការងារ ដើម្បីអនុវត្តបេសកកម្ម ក្នុងគោលបំណងសម្រេចឱ្យបាននូវទិសដៅជាយុទ្ធសាស្ត្រទាំង ៥ របស់ក្រសួងព័ត៌មាន។ លទ្ធផលដែលទទួលបានពីដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រនេះ គឺជាការរួមចំណែកដល់ការអនុវត្តឱ្យបានជោគជ័យយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល។

ជាមួយនឹងគោលដៅជាយុទ្ធសាស្ត្រទាំង ៥ ដែលផ្តោតលើកំណែទម្រង់ការគ្រប់គ្រងនិងដំណើរការការងាររដ្ឋបាលដើម្បីធានានូវប្រសិទ្ធភាពនិងគុណភាពការងារ ការកំណត់បទដ្ឋានច្បាប់/គតិយុត្ត និងបទដ្ឋានបច្ចេកទេសព្រមទាំងប្រព័ន្ធវាយតម្លៃការងារ ការកសាងនិងអភិវឌ្ឍសមត្ថភាពជំនាញគ្រប់គ្រងដឹកនាំនិងជំនាញបច្ចេកទេស ការគ្រប់គ្រងលំហាព័ត៌មានប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាពដោយផ្អែកលើមូលដ្ឋាន នៃការផ្តល់ព័ត៌មានទូលំទូលាយនិងទាន់សភាពការណ៍ប្រកបដោយគុណភាពនិងសុវត្ថិភាព និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគីដើម្បីផលប្រយោជន៍រួម ក្រសួងព័ត៌មានរំពឹងថានឹងសម្រេចបាននូវទិសដៅយុទ្ធសាស្ត្រជាដំណាក់កាលៗ និងឈានទៅសម្រេចបាននូវចក្ខុវិស័យ នៃការប្រែក្លាយជាស្ថាប័នទំនាក់ទំនងសាធារណៈរបស់រាជរដ្ឋាភិបាលប្រកបដោយបុរេសកម្ម សកម្ម អន្តរសកម្ម ប្រសិទ្ធភាព និងប្រសិទ្ធផល។

តាមរយៈផែនការយុទ្ធសាស្ត្រនេះ ក្នុងរយៈពេល ៥ ឆ្នាំ បន្តទៅមុខ ក្រសួងព័ត៌មានរំពឹងនឹងសម្រេចនូវសមិទ្ធិផល និងលទ្ធផលការងារជូនរាជរដ្ឋាភិបាល ជាពិសេសពាក់ព័ន្ធការងារ៖

- ធានាបាននូវសន្តិសុខព័ត៌មាន និងកសាងទំនុកចិត្តលើរាជរដ្ឋាភិបាល និងរក្សាលំនឹងសេរីភាពសារព័ត៌មាន និងសិទ្ធិនៃការបញ្ចេញមតិ

- ការបង្កើនប្រសិទ្ធភាពការងារ លើកកម្ពស់ឧត្តមភាព និងសណ្តាប់ធ្នាប់ក្នុងវិស័យព័ត៌មាន និងសោតទស្សន៍
- លើកកម្ពស់សិទ្ធិ និងសេរីភាពសារព័ត៌មាន ដោយបង្កើនប្រសិទ្ធភាពនៃការអនុវត្តច្បាប់ស្តីពីរបបសារព័ត៌មាន និងពង្រឹងសណ្តាប់សារព័ត៌មាន (បង្កើនគុណភាព និងស្ថេរភាពសារព័ត៌មាន)
- ពង្រឹងការអនុវត្តក្រមសីលធម៌ និងវិជ្ជាជីវៈសារព័ត៌មាន ដើម្បីគ្រប់គ្រង និងលុបបំបាត់ភាពអាណាធិបតេយ្យអ្នកសារព័ត៌មានប្រជាពលរដ្ឋ និងអ្នកសារព័ត៌មានមិនមានវិជ្ជាជីវៈ
- រៀបចំរដ្ឋបាលឯកភាពក្នុងការដឹកនាំនិងគ្រប់គ្រង ដើម្បីពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពការងារ ស្របតាមបរិបទនៃការអភិវឌ្ឍបច្ចេកវិទ្យា និងពង្រីកវិសាលភាពនៃការទទួលខុសត្រូវលើការគ្រប់គ្រងលំហព័ត៌មាន និងសន្តិសុខព័ត៌មាន
- លើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់គ្រងរដ្ឋបាល ធនធានមនុស្ស និងហិរញ្ញវត្ថុ និងបង្កើនការចែករំលែកចំណេះដឹង និងព័ត៌មានក្នុងការងារ ដើម្បីធានាគុណភាពនិងប្រសិទ្ធភាពនៃការផ្តល់និងទទួលសេវាការងាររដ្ឋបាល ដោយពង្រឹងភាពជាម្ចាស់លើការងារ និងភារកិច្ច (លើកកម្ពស់ប្រសិទ្ធភាពការងារ និងការទទួលខុសត្រូវខ្ពស់)
- លើកកម្ពស់ប្រសិទ្ធភាព នៃការធ្វើសមាហរណកម្មតំបន់ក្នុងវិស័យព័ត៌មាន ដើម្បីបង្កើនសង្គត់ភាពស្របតាមក្របខណ្ឌតំបន់និងបទដ្ឋានអន្តរជាតិ
- ពង្រីកវិសាលភាព ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធផ្សព្វផ្សាយ តាមរយៈការបង្កើនភាពដៃគូរវាងរដ្ឋ និងឯកជននៅក្នុងដំណើរការអភិវឌ្ឍប្រទេសកម្ពុជា
- កែលម្អប្រព័ន្ធគ្រប់គ្រងការងាររដ្ឋបាល និងលើកកម្ពស់វិជ្ជាជីវៈក្នុងការងារ
- បង្កើនតម្លាភាព និងលើកកម្ពស់បរិយាកាសការងារដោយកាត់បន្ថយនូវបញ្ហាសតិអារម្មណ៍
- ការផ្តល់សេវាកម្មប្រកបដោយគុណភាព ការអនុវត្តការងារជាក្រុម ការអភិវឌ្ឍសមត្ថភាពជំនាញ ការបង្កើតនូវទំនាក់ទំនងល្អក្នុងការងារ ការទទួលបាននូវឱកាសស្មើគ្នា (សមធម៌ក្នុងការងារ) ការទទួលស្គាល់នូវគំនិតផ្តួចផ្តើមនិងលើកទឹកចិត្តក្នុងការប្រកួតប្រជែង ការផ្តល់នូវអត្ថប្រយោជន៍ផ្អែកលើប្រសិទ្ធភាពការងារ
- ធានាបាននូវសណ្តាប់ធ្នាប់ក្នុងការផ្តល់ និងផ្សព្វផ្សាយព័ត៌មានដែលពាក់ព័ន្ធនឹងកម្ពុជា
- គ្រប់គ្រងដោយប្រសិទ្ធភាពសាធារណមតិជាតិ និងអន្តរជាតិ ដោយរក្សានូវសន្តិសុខនិងលំហសេរីភាពសារព័ត៌មាន តាមរយៈការប្រឆាំងនិងទប់ស្កាត់ការជ្រៀតជ្រែករបស់បរទេស ដើម្បីការពារសមិទ្ធផល និងកេរ្តិ៍ឈ្មោះកម្ពុជា (ការពារកេរ្តិ៍ឈ្មោះ កិត្យានុភាព និងអធិបតេយ្យភាពកម្ពុជានៅលើឆាកអន្តរជាតិ)
- លើកកម្ពស់ប្រសិទ្ធភាពការងារព័ត៌មានជូនដល់សាធារណជនជាតិនិងអន្តរជាតិអំពីការងារ សមិទ្ធផល និងគោលនយោបាយ (កសាង និងបន្តលើកកម្ពស់ទំនុកចិត្តមកលើកម្ពុជា)
- សម្របសម្រួលឱ្យមានឯកភាព ប្រសិទ្ធភាព និងសណ្តាប់ធ្នាប់ក្នុងការផ្តល់និងផ្សាយព័ត៌មានពាក់ព័ន្ធនឹងសមិទ្ធផលការងារ និងគោលនយោបាយរាជរដ្ឋាភិបាល

- លើកកម្ពស់ការដឹកនាំ និងគ្រប់គ្រងការផ្សព្វផ្សាយដោយសម្របសម្រួលជាមួយបណ្តាញសារព័ត៌មានផ្លូវការ និងបណ្តាញទំនាក់ទំនងសង្គមជាតិនិងអន្តរជាតិដើម្បីគ្រប់គ្រងលំហូព័ត៌មានឱ្យកាន់តែមានប្រសិទ្ធភាព
